គ្រួសារយើង
KROUSAR YOEUNG

# របាយការណ៍ប្រចាំឆ្នាំ២០១៤



កុមារមានឱកាសទទួលបាន
ការអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយ



ការប្រឹក្សាយោបល់ជាមួយ
គ្រួសារក្រីក្រ

**សមាគមគ្រួសារយើងមានជំនាញយ៉ាងច្បាស់លាស់លើ៖**

- ការងារថែទាំគាំពារ អប់រំ និងអភិវឌ្ឍកុមារតូច ដើម្បីឆ្លើយតបទៅនឹងសិទ្ធិកុមារ តម្រូវការរបស់កុមារ ព្រមទាំងកសាងមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍប្រទេសជាតិ។
- លើកកម្ពស់ការយល់ដឹងនិងការទទួលខុសត្រូវរបស់ឪពុកម្តាយក្នុងការថែទាំ អប់រំ និងអភិវឌ្ឍន៍កូន។
- ការងារប្រឹក្សាយោបល់ក្នុងគោលបំណងធ្វើការផ្លាស់ប្តូរផ្នត់គំនិត ដល់ប្រជាជនក្រីក្របំផុត និងជនងាយរងគ្រោះ (ជនពិការ ជនជាតិដើមភាគតិច អ្នកផ្ទុកមេរោគអេដស៍ កុមារជាមេគ្រួសារ ស្រ្តីជាមេគ្រួសារ) ដើម្បីឱ្យពួកគាត់ទទួលបានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តតាមបែបចូលរួមក្នុងគ្រួសារ និងសហគមន៍ ព្រមទាំងលើកកម្ពស់កម្រិតជីវភាព សុខភាព ការអប់រំឱ្យប្រសើរឡើង។
- ការបន្សាំនឹងបម្រែបម្រួលអាកាសធាតុនៅតាមសាលាមត្តេយ្យ សាលាបឋមសិក្សានិងក្នុងសហគន៍។



# សាររបស់ប្រធានក្រុមប្រឹក្សាភិបាល

ក្នុងរយៈពេល១៤ឆ្នាំកន្លងមកនេះ សមាគមគ្រួសារយើង បានអនុវត្តតួនាទីយ៉ាងសំខាន់ក្នុងការងារអភិវឌ្ឍ ទាំងតំបន់ជនបទ និងតំបន់ជាយរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ដោយផ្តោតលើវិស័យគាំពារ និងអភិវឌ្ឍន៍កុមារតូច និងការពង្រឹងសិទ្ធិអំណាចរបស់សហគមន៍ (ជាពិសេសគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះបំផុត) ដោយបានប្រើប្រាស់អភិក្រមចម្រុះសម្រាប់ធ្វើការអភិវឌ្ឍន៍។

ការអនុវត្តន៍សកម្មភាពរបស់សមាគមគ្រួសារយើង បានរួមចំណែកយ៉ាងសកម្មក្នុងការកាត់បន្ថយភាពក្រីក្រតាមរយៈការពង្រឹងគុណភាពវិស័យអប់រំ ដែលក្នុងនោះសមាគម បានជ្រើសយកការងារអប់រំកុមារតូចជាមូលដ្ឋានគ្រឹះក្នុងការអនុវត្តន៍ការងារស្នូលរបស់ខ្លួន។

បច្ចុប្បន្ន ខ្ញុំសង្កេតឃើញថា បុគ្គលិកសមាគមគ្រួសារយើងពិតជាមានឆន្ទៈមុះមុត និងមានសមត្ថភាពអនុវត្តការងារប្រកបដោយវិជ្ជាជីវៈ និងមានលក្ខណៈអាជីព ដែលធ្វើឱ្យសមាគមគ្រួសារយើងកាន់តែមានការទទួលស្គាល់ និងគាំទ្រជាបន្តបន្ទាប់ពីម្ចាស់ជំនួយ ដៃគូអភិវឌ្ឍ អាជ្ញាធរមូលដ្ឋាន មន្ត្រីរាជរដ្ឋាភិបាល គ្រួសារដៃគូ និងអ្នកពាក់ព័ន្ធផ្សេងទៀត និងទទួលបាននូវលទ្ធផលគួរឱ្យកត់សម្គាល់។ ដោយសារបុគ្គលិកមានភាពចាស់ទុំ ក្នុងបទពិសោធន៍ការងារអភិវឌ្ឍន៍កុមារតូច ក្នុងឆ្នាំ២០១៤នេះ សមាគមគ្រួសារយើងបានទទួលថវិកាចំនួន**៩៦៦,៩២៣**ដុល្លារអាមេរិក ពីម្ចាស់មូលនិធិចំនួន៩ សម្រាប់អនុវត្តគម្រោងចំនួន៦ នៅក្នុងខេត្តគោលដៅចំនួនប្រាំពីរគឺ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តរតនគីរី កណ្តាល តាកែវ កំពង់ស្ពឺ និងតំបន់ជាយរាជធានីភ្នំពេញ។

តាមរយៈការអនុវត្តន៍គម្រោងទាំងនេះ សមាគមគ្រួសារយើងបានជួយដល់គ្រួសារក្រីក្រនិងក្រុមជនងាយរងគ្រោះបំផុត បង្កើននូវភាពជឿជាក់លើខ្លួនឯង ហើយមានឱកាស និងលទ្ធភាពអភិវឌ្ឍគ្រួសាររបស់ពួកគេប្រកបដោយជោគជ័យ ជាពិសេសការគោរពសិទ្ធិកុមារ និងជួយដល់កុមារឱ្យទទួលបាននូវការអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយ ។

ក្នុងនាមខ្លួនខ្ញុំផ្ទាល់ និងតំណាងឲ្យសមាជិក សមាជិការបស់ក្រុមប្រឹក្សាភិបាលសមាគមគ្រួសារយើង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ម្ចាស់ជំនួយ ដៃគូអភិវឌ្ឍន៍ និងគ្រប់ភាគីពាក់ព័ន្ធ ដែលបានរួមចំណែកជួយគាំទ្រដល់ការអនុវត្តន៍គម្រោងរបស់សមាគមគ្រួសារយើង រហូតសម្រេចបានសមិទ្ធផលដូចបានពណ៌នាក្នុងរបាយការណ៍នេះ។ យើងខ្ញុំសង្ឃឹមថាគ្រប់ភាគីពាក់ព័ន្ធនឹងបន្តកិច្ចសហប្រតិបត្តិការ ព្រមទាំងផ្តល់ការគាំទ្រដល់សមាគមគ្រួសារយើងដើម្បីបន្តលើកស្ទួយការគោរពសិទ្ធកុមារ និងអភិវឌ្ឍកុមារគ្រប់ជ្រុងជ្រោយនៅក្នុងព្រះរាជាណាចក្រកម្ពុជា៕

ភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥

**ច័ន្ទ មុន្នីរ័ត្ន័**



# សាររបស់នាយិកាសមាគមគ្រួសារយើង

កុមារគ្រប់រូបបានបង្ហាញសមត្ថភាពគួរឱ្យកោតសរសើរតាំងពីកើតមកម្ល៉េះ។ តម្រូវការទំនាក់ទំនង និងការទទួលឥទ្ធិពលពីគ្នាទៅវិញទៅមកជាមួយនិងមនុស្ស សត្វ វត្ថុ បាតុភូតធម្មជាតិ សម្បត្តិវប្បធម៌ ដែលនៅជុំវិញខ្លួនរបស់កុមារមានសារសំខាន់ណាស់ ។

ដើម្បីអភិវឌ្ឍរាងកាយ ភាសា សតិបញ្ញា សញ្ចេតនាសង្គម កុមារត្រូវការក្តីស្រលាញ់ អាហារូបត្ថម្ភព្រមទាំងការថែទាំពេញលេញ កុមារត្រូវការអ្នកនៅជុំវិញខ្លួនគេសន្ទនា ជាមួយដោយទឹកមុខរីករាយ សម្លេងពិរោះទន់ភ្លន់ ផ្តល់ភាពកក់ក្តៅ។ កុមារត្រូវការបរិស្ថានមួយដែលមានការលើកទឹកចិត្ត ឱ្យគេអាចស្រាវជ្រាវ បង្កើតថ្មី មនុស្សជុំវិញពួកគេជួយឱ្យគេយល់ពីអ្វីៗជុំវិញខ្លួន និងប្រាប់អត្ថន័យនៃបទពិសោធន៍របស់ពួកគេ។

វ័យដែលកុមារកសាងបាននូវមូលដ្ឋានគ្រឹះនៃបុគ្គលិកលក្ខណៈហើយកំនត់ឥរិយាបថ បំនិនផ្នែកបញ្ញា ស្មារតីសង្គម ពេលក្លាយជាមនុស្សពេញវ័យគឺ ឋិតនៅក្នុងដំណាក់កាលអាយុ ៦ឆ្នាំដំបូងនៃជីវិត។

ចង់បានសង្គមមួយមានការអភិវឌ្ឍន៍ពេញលេញ សុខសន្តិភាព យុត្តិធម៌ ត្រូវចាប់ផ្តើមចេញពីកុមារ ដើម្បីកុមារមានមូលដ្ឋានគ្រឹះនៃបុគ្គលិកលក្ខណៈក្លាយជាមនុស្សសំខាន់អាចអភិវឌ្ឍប្រទេសជាតិបានលុះត្រាតែ គ្រួសារ សង្គមនៅជុំវិញកុមារមានលទ្ធភាពឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ។

ការសិក្សាស្រាវជ្រាវកន្លងមកបង្ហាញឱ្យឃើញថាសារសំខាន់ ក្នុងការយកចិត្តទុកដាក់ចំពោះកុមារនៅក្នុងដំណាក់កាលដំបូងនៃជីវិត (0-៦ឆ្នាំ) នេះ ត្រូវបានគេមើលរំលង។

នេះជាហេតុផលដែលសមាគមគ្រួសារយើងកំណត់យកការអភិវឌ្ឍន៍កុមារតូច ជាមូលដ្ឋានគ្រឹះលើគ្រប់សកម្មភាពរបស់ខ្លួន។

ចាប់តាំងពីឆ្នាំ ២០០១ មកគ្រួសារយើងបន្តសកម្មភាពអប់រំកុមារតូចពីអង្គការកុមារ និងអភិវឌ្ឍន៍ រហូតមកដល់ឆ្នាំ ២០១៤នេះ។

គ្រួសារយើងបានអនុវត្តផែនការយុទ្ធសាស្ត្ររបស់ខ្លួនចំនួន២ដំណាក់កាលរួចហើយគឺ ដំណាក់កាលទី១ ឆ្នាំ ២០០២ - ២០០៧ និងដំណាក់កាលទី២ ឆ្នាំ ២០០៨ - ២០១៣។

គ្រួសារយើងមានកម្មវិធីចម្បងចំនួន៣ គឺៈ

- ការថែទាំ គាំពារ និងអភិវឌ្ឍកុមារតូច
- លើកកម្ពស់ការអនុវត្តសិទ្ធិកុមារ និងសិទ្ធមនុស្ស
- ពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់គ្រួសារ

ដំណាក់កាលទី៣ ឆ្នាំសិក្សា ២០១៤ - ២០១៨ យើងនៅតែអនុវត្តកម្មវិធីចម្បងទាំងបីដែលមានផែនការយុទ្ធសាស្ត្រកាន់តែជាក់លាក់និងសុក្រិត ដោយពង្រឹងភាពជាដៃគូ ការស្វែងរកការគាំទ្រ ការកសាងសមត្ថភាព ការសម្រួចកិច្ចអន្តរាគមន៍ឱ្យកាន់តែមានប្រសិទ្ធភាព។

កម្មវិធីទាំងអស់នេះសុទ្ធតែទទួលបានលទ្ធផលគួរជាទីមោទនភាព។ រយៈពេល ២ឆ្នាំចុងក្រោយ ឆ្នាំ ២០១៣-២០១៤ នេះកម្មវិធីថែទាំ គាំពារ និងអភិវឌ្ឍន៍កុមារតូច បានពង្រីកទៅដល់ខេត្តរតនគីរី កត្តានិរន្តរភាពបានលេចឡើងកាន់តែច្បាស់ នៅគ្រប់តំបន់ការងារព្រមទាំងមានសក្តានុពលភាព សាលាមត្តេយ្យដែលស្វយ័តភាពចាប់ពីឆ្នាំ២០០២-២០០៣ មកនៅតែបន្តនិរន្តរភាពតាមរយៈរូបភាពខុសៗគ្នា។ យើងបានសហការជាមួយអង្គការភ្លែន ផ្តួចផ្តើមគំនិតបង្កើតសាលាមត្តេយ្យចល័តសម្រាប់កុមារ ដែលគ្រួសារពួកគេមានបន្លាស់ទី

រយៈពេលយូរទៅកន្លែងធ្វើស្រែចំការឆ្ងាយពីលំនៅស្ថានចំនួន ពីរកន្លែងនៅគឺនៅភូមិឃ្លួន ឃុំកាចូនស្រុកវ៉ឺនសៃ និងនៅភូមិផាវ ឃុំតាវែងក្រោម ស្រុកតាវែង ខេត្តរតនគីរី។ ឆ្នាំនេះយើងបានលើកទឹកចិត្តនិងប្រឹក្សាជាមួយក្រុមប្រឹក្សាឃុំ ឱ្យបង្កើនកិច្ចសហការជាមួយគណៈកម្មការទ្រទ្រង់សាលា ស្វែងយល់ពីតម្រូវការរបស់សាលា រួចលើកយកតម្រូវការនេះទៅដាក់បញ្ចូលក្នុងផែនការវិនិយោគឃុំរបស់គាត់។ ជាលទ្ធផល ក្រុមប្រឹក្សាឃុំអាច ជួយឧបត្ថម្ភគ្រូមត្តេយ្យសហគមន៍ព្រមទាំងផ្សព្វផ្សាយពីសារៈសំខាន់របស់ការងារអប់រំកុមារតូច ដល់ប្រជាជន ព្រះសង្ឃ ក្នុងមូលដ្ឋាន ហើយគៀគរប្រមូលការគាំទ្រដល់សាលាមត្តេយ្យជាហូរហែតាមរដូវដែលវត្តអារាមនិងប្រជាជនទទួលបានថវិកា។

មជ្ឈមណ្ឌលធនធានបានពង្រីកតួនាទីរបស់ខ្លួនកាន់តែមានប្រសិទ្ធភាព ព្រឹត្តិប័ត្តព័ត៌មានត្រូវបានអ្នកពាក់ព័ន្ធអាន និងយកជាមេរៀនបទពិសោធន៍។ ការអភិវឌ្ឍន៍មជ្ឈមណ្ឌលធនធានត្រូវបានទទួលស្គាល់នៅតំបន់អាស៊ី និងផ្សព្វផ្សាយទៅតំបន់អាហ្វ្រិក (Bukinafaso)។ កម្មវិធីលើកកម្ពស់សិទ្ធកុមារក៏មានសក្តានុពលភាពទាំងក្នុងគ្រួសារ និងសង្គម កុមារត្រូវបានថែទាំ បំប៉ន និងបញ្ជូនទៅរៀនចាប់ពីមត្តេយ្យសិក្សា ដល់មធ្យមសិក្សា។ គ្រួសារចំនួន១៤៨៤ គ្រួសារត្រូវ៧៨.២៤% នៃគ្រួសារក្រីក្រក្នុងតំបន់បានវាយតម្លៃថាមានភាពម្ចាស់កា និងការទទួលខុសត្រូវទាំងផ្នែកសេដ្ឋកិច្ច សុខភាព អប់រំ សង្គម ហើយចេញពីពួកគាត់។ គ្រួសារយើងចូលរួមយ៉ាងសកម្មក្នុងដំណើរការចងក្រងគោលនយោបាយជាតិស្តីពីការថែទាំ គាំពារ និងអភិវឌ្ឍន៍កុមារតូច ព្រមទាំងសហការជាមួយក្រសួងពាក់ព័ន្ធមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ រហូតថ្នាក់ក្រោមជាតិ។ បណ្តាញអង្គការធ្វើការងារអប់រំថែទាំកុមារតូចនៅតែបន្តតួនាទីយ៉ាងសំខាន់ក្នុងការចែកចាយ និងផ្លាស់ប្តូរបទពិសោធន៍ក្នុងការអនុវត្តគម្រោងគាំពារនិងថែទាំកុមារតូច។

នៅក្នុងឱកាសសន្និបាតរបស់សមាគមឆ្នាំ ២០១៤ នេះ នាងខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលិកទាំងអស់ដែលតស៊ូស្វិតស្វាញ ជំនះគ្រប់ឧបសគ្គ ព្រមទាំងគ្រួសារដៃគូក្រីក្ររហូតដល់ថ្នាក់ដឹកនាំពីគ្រប់វិស័យ និងដៃគូសង្គមស៊ីវិល ព្រមទាំងម្ចាស់ជំនួយដែលបានសហការជាមួយ សមាគមគ្រួសារយើង ជម្រុញឱ្យយើងទទួលបានលទ្ធផលគួរឱ្យមោទនភាព។

នាងខ្ញុំសូមបញ្ជាក់ជាថ្មីម្តងទៀតពីការប្តេជ្ញាចិត្តរបស់សមាគមគ្រួសារយើង ក្នុងការខិតខំអនុវត្តការងារដើម្បីធានាថាកុមារទទួលបានសិទ្ធិដែលពួកគេមាន ឪពុកម្តាយ និងអ្នកនៅជុំវិញកុមារមានភាពម្ចាស់ការ និងទទួលខុសត្រូវចំពោះកុមារ ពួកគាត់មានសមត្ថភាព និងលទ្ធភាពឆ្លើយតបទៅនឹងតម្រូវការរបស់កូនៗ។

សូមឯកឧត្តម លោកជំទាវ លោកស្រី-លោកទាំងអស់ចូលរួមសហការជាមួយយើងខ្ញុំ។

ភ្នំពេញ ថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០១៤

**គី សំគី**

# មាតិកា

ទំព័រ

១. សមាគមគ្រួសារយើងជានរណា?........................................................................................១
១ .១.ទស្សនវិស័យ........................................................................................................១
១.២. បេសកកម្ម...........................................................................................................១
១.៣. គុណតម្លៃ.............................................................................................................២
២. សមាគមគ្រួសារយើងធ្វើការងារអ្វីខ្លះ?.............................................................................៤
២.១. និមិត្តសញ្ញានៃសកម្មភាពសំខាន់ៗ...........................................................................៤
២.២. គម្រោងដែលបានអនុវត្តក្នុងឆ្នាំ២០១៤.........................................................................៥
២.៣. អភិក្រម និងវិធីសាស្ត្រក្នុងការអនុវត្តន៍ការងារ.................................................................៦
២.៣.១. អភិក្រមសមាហរណកម្មកម្មវិធី.............................................................................៦
២.៣.២. ភាពជាដៃគូការងារ...........................................................................................៦
២.៣.៣. សកម្មភាពយកសិទ្ធិមនុស្សជាមូលដ្ឋានក្នុងការអភិវឌ្ឍន៍សហគមន៍...........................៦
៣. តំបន់ប្រតិបត្តិការ និងអ្នកទទួលផលក្នុងឆ្នាំ២០១៤.............................................................៧
៤. សកម្មភាពសំខាន់ៗក្នុងឆ្នាំ២០១៤.....................................................................................៨
៤.១. ការងារអភិវឌ្ឍកុមារតូច និងលើកកម្ពស់សិទ្ធិកុមារ..........................................................៨
៤.១.១. បង្កើតសាលាមត្តេយ្យសហគមន៍ប្រកបដោយគុណភាព និងនិរន្តរភាព..................៨
៤.១.២. គាំទ្រការងារអប់រំរបស់ឪពុកម្តាយចំពោះកូនៗ.................................................១២
៤.១.៣. មជ្ឈមណ្ឌលធនធានកុមារតូច.......................................................................១៦
- ការងារបណ្តុះបណ្តាល.......................................................................................១៦
-ការចងក្រងឯកសារ (ប្រមូល កែលម្អ បង្កើតថ្មី និងផលិតសម្ភារតុកោសល្យ)......២១
-ការចែករំលែកបទពិសោធន៍ទាក់ទងនឹងការងារអប់រំកុមារតូច..........................២៦
៤.២. ក្លឹបកុមារ  ការរៀនសូត្រ និងការលើកកម្ពស់ការគោរពសិទ្ធិកុមារ...............................២៩
៤.៣. ការគាំទ្រ និងការពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់គ្រួសារ.................៣២
៤.៣.១. ការប្រឹក្សាយោបល់ជាមួយគ្រួសារក្រីក្រ.....................................................៣៣
៤.៣.២. ការអភិវឌ្ឍន៍ជីវភាពគ្រួសារ........................................................................៣៧
៤.៣.៣. ការលើកស្ទួយសុខភាពគ្រួសារ.....................................................................៤២
៤.៣.៤. ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជន យុវនារីក្រីក្រ ងាយរងគ្រោះអាយុ១៥-២៤ ឆ្នាំដែលបោះបង់ការសិក្សា..................................................................................៤៥
៥. ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍ.......................................................................................៤៩
៥.១. ម្ចាស់ជំនួយ......................................................................................................៤៩

៥.២. ដៃគូសហការអភិវឌ្ឍ..........................................................................................៤៩
៦. ស្ថានភាពហិរញ្ញវត្ថុ ឆ្នាំ២០១៤..........................................................................................៥០
៧. ផែនការយុទ្ធសាស្ត្រឆ្នាំ២០១៤-២០១៨..........................................................................................៥២
៨. គម្រោងសកម្មភាព និងថវិកាឆ្នាំ២០១៥..........................................................................................៥៤
ឧបសម្ព័ន្ធ:
ឧបសម្ព័ន្ធទី១៖ តំបន់ប្រតិបត្តិការក្នុងឆ្នាំ២០១៤..........................................................................................៥៧
ឧបសម្ព័ន្ធទី២៖ អ្នកទទួលផលផ្ទាល់ពីគម្រោងក្នុងឆ្នាំ២០១៤..........................................................................................៥៩
ឧបសម្ព័ន្ធទី៣៖ សាលាដែលបានសាងសង់ និងជួសជុលក្នុងឆ្នាំសិក្សា២០១៣-២០១៤....៦១
ឧបសម្ព័ន្ធទី៤៖ ស្ថិតិសាលាមត្តេយ្យស្វ័យភាព..........................................................................................៦៣
ឧបសម្ព័ន្ធទី៥៖ ស្ថិតិកុមារចូលរៀននៅសាលាមត្តេយ្យសហគមន៍..........................................................................................៦៦

## ១. សមាគមគ្រួសារយើងជានរណា?

គ្រួសារយើង ជាសមាគមខ្មែរក្នុងស្រុកមួយ ដែលបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់សុខុមាលភាព បញ្ញា និងការអភិវឌ្ឍន៍របស់កុមារ ពង្រឹងសមត្ថភាពថែទាំ និងអប់រំរបស់ឪពុកម្តាយចំពោះកូនៗ និងបង្កើនជីវភាព ភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់គ្រួសារក្រីក្រ ដោយពុំស្វែងរកកម្រៃ មិនប្រកាន់សាសនា និងនិន្នាការនយោបាយណាមួយឡើយ។ សមាគមគ្រួសារយើង ត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០១ ហើយបានទទួលស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០២។

### ១.១. ទស្សនវិស័យ

សមាគមគ្រួសារយើង ចង់ឱ្យកុមារកម្ពុជាលូតលាស់ប្រកបដោយទំនុកចិត្ត ព្រមទាំងទទួលផលពីបរិស្ថានដែលមានលក្ខណៈជម្រុញការអភិវឌ្ឍ និងការគោរពអនុសញ្ញាសិទ្ធិកុមារ ព្រមទាំងសេចក្តីត្រូវការរបស់ពួកគេ ។

### ១.២. បេសកកម្ម

បេសកកម្មរបស់សមាគមគ្រួសារយើងគឺដើម្បី ចូលរួមក្នុងការបង្កើតឱ្យមានបរិស្ថានសមស្របក្នុងការអភិវឌ្ឍន៍ទូទៅនិងគ្រប់ជ្រុងជ្រោយ រួមមានការអភិវឌ្ឍន៍បញ្ញា ភាសា រាងកាយ ភាពសុខុដុមរមនា និងលក្ខខណ្ឌរស់នៅសមរម្យ។ ដើម្បីសម្រេចបានដូចខាងលើ សមាគមមានមហិច្ឆិតាក្នុងការៈ

- គាំទ្រការអនុវត្តន៍កម្មវិធីអប់រំកុមារតូចឱ្យស្របទៅតាមបរិបទនិងភាពជាក់ស្តែងនៃប្រជាជនក្នុងភូមិ។
- ធ្វើការងារដើម្បីបង្កើនគុណភាពនៃជំនាញការងារអប់រំឪពុកម្តាយចំពោះកូនៗ និងអន្តរកម្មរវាងឪពុកម្តាយនិងកូន។
- ចែករំលែកការងារអភិវឌ្ឍកុមារ និងធ្វើឱ្យប្រសើរឡើងនូវការងារអប់រំកុមារតូច ព្រមទាំងបង្ការ ពង្រឹងសិទ្ធអំណាចរបស់គ្រួសារ ជាមួយរដ្ឋអំណាចមូលដ្ឋាន អង្គការជាតិ និងអន្តរជាតិ ព្រមទាំងម្ចាស់អំណោយ។
- ចូលរួមអភិវឌ្ឍធនធានមនុស្សដែលមានជំនាញក្នុងវិស័យអប់រំកុមារតូច និងការបន្សាំុនឹងបម្រែបម្រួលអាកាសធាតុ។
- គ្របតំបន់ការងារទាំងអស់គ្រួសារយើងប្តេជ្ញាបញ្ចូលក្រុមជនជាតិភាគតិចនិងកុមារពិការទៅក្នុងគម្រោងរបស់ខ្លួន។
- ផ្តល់ជូននៅឱកាសពិសេសដល់កុមារីជនបទនិងយុវតីវ័យក្មេងដើម្បីទទួលបានសេវាអប់រំយ៉ាងមានប្រសិទ្ធិភាព។
- ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ចសង្គមរបស់គ្រួសារតាមរយៈសកម្មភាពពង្រីកភាពម្ចាស់ការ។

- ផ្តល់ការគាំទ្រក្នុងទម្រង់ជាការប្រឹក្សាបច្ចេកទេសនិងធនធានមនុស្ស ដល់ក្រសួង អង្គការជាតិ អង្គការអន្តរជាតិ ក្នុងវិស័យអប់រំកុមារតូច ការងារអប់រំរបស់ឪពុកម្តាយចំពោះកូនៗ និងសកម្មភាពសាលាកុមារមេត្រី។
- លើកស្ទួយការគាំទ្រជាមូលដ្ឋានលើសិទ្ធកុមារ ការអប់រំកុមារតូច ការពង្រឹងភាពម្ចាស់ការគ្រួសារ ទាំងថ្នាក់ជាតិនិងអន្តរជាតិ។
- ចែករំលែកបទពិសោធន៍បច្ចេកទេសជាមួយបណ្តាញនៃស្ថាប័នរដ្ឋដែលពាក់ព័ន្ធ អង្គការដៃគូ និងវិស័យឯកជន។

## ១.៣. គុណតម្លៃ

### ១.៣.១. សុខុមាលភាព និងការគោរពសិទ្ធិរបស់កុមារ

កុមារមានសុខភាពល្អ កុមារអភិវឌ្ឍរាងកាយ បញ្ញា ស្មារតី សញ្ចេតនាសង្គម តាមរយៈ សកម្មភាពរបស់គេ។ កុមារត្រូវការធ្វើសកម្មភាព រុករក និងស្រាវជ្រាវស្វែងយល់នៅក្នុងពិភពជុំវិញខ្លួនដោយខ្លួនគេ។ កុមារត្រូវការបរិស្ថានសមស្រប និងលើកទឹកចិត្តដែលនឹងអាចឈានទៅរកភាពម្ចាស់ការ ព្រមទាំងបង្កឱកាសឱ្យកុមារអភិវឌ្ឍបំនិនផ្ទាល់ខ្លួនឱ្យឆ្លើយតបនឹងចំណាប់អារម្មណ៍ខ្ពស់បំផុតរបស់គេ។

### ១.៣.២. ការគោរពសេចក្តីថ្លៃថ្នូរ និងភាពសុខដុមរបស់គ្រួសារ

ក្នុងនាមជាកោសិកាមូលដ្ឋានរបស់សង្គម គ្រួសារនៅតែជាស្ថាប័នគ្រឹះរបស់សង្គមដែលធានាឱ្យមានសុវត្ថិភាព ចំណីអាហារ សុខុមាលភាព ការការពារ និងទំនាក់ទំនងយ៉ាងជិតស្និទ្ធ រវាងសមាជិកទាំងអស់ក្នុងគ្រួសារ។ ដូច្នេះគ្រួសារ ត្រូវទទួលបានការការពារ ព្រមទាំងពង្រឹងសមត្ថភាពទាក់ទងនឹងជំនាញការងារអប់រំរបស់ឪពុកម្តាយចំពោះកូនៗនិងជំនាញការសម្របទៅនឹងការបម្រែបម្រួលអាកាសធាតុ។

### ១.៣.៣. ការគោរពសិទ្ធិមនុស្ស ជាពិសេសជនងាយរងគ្រោះនិងភាពម្ចាស់ការរបស់មនុស្ស និងសហគមន៍

គ្រប់សកម្មភាពរបស់សមាគមគ្រួសារយើង ត្រូវសំដៅទៅរកភាពរឹងមាំ និងម្ចាស់ការរបស់មនុស្ស និងសហគមន៍ ទាំងមូល។

### ១.៣.៤. ភាពជាដៃគូអភិវឌ្ឍន៍ (កុមារ គ្រួសារ អ្នកមានកាតព្វកិច្ច ស្ថាប័នផ្សេងៗ អង្គការជាតិ អន្តរជាតិ និងស្ថាប័នឯកជន)

គ្រួសារយើងពង្រឹងនិងបង្កើតឡើងនូវធនធាននៅក្នុងសហគមន៍តាមរយៈការពិភាក្សាយ៉ាងជិតស្និទ្ធរវាងកុមារ គ្រួសារ អ្នកមានកាតព្វកិច្ច និង អង្គការដែលផ្តល់សេវាជាមូលដ្ឋាននៅក្នុងភូមិ។ គ្រួសារយើង គាំទ្រការសហការរវាងដៃគូនិងឱ្យតម្លៃទៅលើចំនុចខ្លាំងនិងធនធានដែលមានស្រាប់ក្នុងគ្រួសារ។

### ១.៣.៥. ប្រសិទ្ធិភាព ប្រសិទ្ធិផល តម្លាភាព គណនេយ្យភាពការងារ

ក្រុមការងាររបស់សមាគមគ្រួសារយើង មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការឱ្យតម្លៃលើប្រសិទ្ធិភាពនិងប្រសិទ្ធិផលការងារ។ គ្រួសារយើងទទួលស្គាល់ពីសារៈសំខាន់ក្នុងការធ្វើឱ្យមានតម្លាភាពនិងគោលការណ៍

គណនេយ្យភាពគ្រប់ការងារដែលយើងធ្វើ មិនមែនចំពោះតែម្ចាស់ជំនួយនិងដៃគូអភិវឌ្ឍន៍នោះទេ តែត្រូវមានចំពោះគ្រប់បុគ្គលិកនិងអ្នកដែលទទួលផលពីគម្រោង។

**១.៣.៦. បញ្ហាបញ្ហារាំងស្ទះទាំងបួន**

សិទ្ធកុមារ ការដាក់បញ្ចូលក្នុងសង្គមរួមទាំងក្រុមដែលត្រូវបានគេរើសអើង ជនពិការ និងសមភាពយេនឌ័រ និងការសម្របតាមការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាដែលត្រូវពិចារណាខ្ពស់ និងបញ្ជ្រាបក្នុងកម្មវិធីដែលគ្រួសារយើងបានអនុវត្ត។



## ២. សមាគមគ្រួសារយើងធ្វើការងារអ្វីខ្លះ?

### ២.១. និមិត្តសញ្ញានៃសកម្មភាពសំខាន់ៗ

**ការគាំពារ និងអភិវឌ្ឍន៍កុមារតូច និងលើកកម្ពស់សិទ្ធិកុមារ**

បង្កើតសាលាមត្តេយ្យសហគមន៍ប្រកបដោយគុណភាព និងនិរន្តរភាព



គាំទ្រការងារអប់រំរបស់ឪពុកម្តាយចំពោះកូនៗ (0 ដល់ ១៨ឆ្នាំ)



ផ្តល់សេវាបណ្តុះបណ្តាលជំនាញគាំពារ និងអភិវឌ្ឍន៍កុមារតូច (បណ្តុះបណ្តាលគ្រូមត្តេយ្យ អ្នកសម្របសម្រួលនិងអ្នកពាក់ព័ន្ធគ្រប់កម្រិត) និងការប្រឹក្សាយោបល់



ក្លឹបកុមារ(លើកកម្ពស់ការរៀនសូត្រ និងការគោរពសិទ្ធិកុមារ)





ពង្រីកនិងពង្រឹងជំនាញការគាំពារនិងអភិវឌ្ឍកុមារតូច (មជ្ឈមណ្ឌលធនធានកុមារតូច) ពង្រីកនិងពង្រឹងបណ្តាញ**ការងារអប់រំ ថែទាំ និងអភិវឌ្ឍកុមារតូច** (សមាគមគ្រួសារយើងត្រូវបានជាប់ឆ្នោត ជាប្រធានបណ្តាញតាំងពីឆ្នាំ ២០០២ ដល់ បច្ចុប្បន្ន) ផលិតល្បែងគរុកោសល្យ និងផ្តល់សេវាសម្រាប់បម្រើដល់ការអភិវឌ្ឍន៍កុមារ

បង្កើនការអភិវឌ្ឍកុមារ (ល្បែងសេរី)



ការពង្រឹងការអនុវត្តន៍កម្មវិធីសាលាកុមារមេត្រី

**ការគាំទ្រ និងការពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់គ្រួសារ**




ប្រឹក្សាយោបល់ជាមួយគ្រួសារក្រីក្រ



ការអភិវឌ្ឍន៍ជីវភាពគ្រួសារ

ការលើកស្ទួយសុខភាពគ្រួសារ





ការបណ្តុះបណ្តាលវិជ្ជាជីវៈ

## ២.២. គម្រោងដែលបានអនុវត្តក្នុងឆ្នាំ២០១៤

| ល.រ | គម្រោង | ម្ចាស់ជំនួយ | សកម្មភាពសំខាន់ៗ | ខេត្តគោលដៅ |
|---|---|---|---|---|
| ១ | ការបង្កើតមជ្ឈមណ្ឌលធនធាន និងកម្មវិធីអប់រំកុមារតូច | សហភាពអឺរ៉ុប អង្គការកុមារនិងអភិវឌ្ឍន៍ និងស្ថានទូតជប៉ុន |      | ភ្នំពេញ កណ្ដាល និងតាកែវ |
| ២ | ល្បែង និងកុមារតូច | កុមារនិងអភិវឌ្ឍន៍ ផ្លូវរបស់កុមារ |   | ភ្នំពេញ កណ្ដាល តាកែវ និងកំពង់ស្ពឺ |
| ៣ | គម្រោងការគាំពារ និងការអភិវឌ្ឍន៍កុមារតូច សម្រាប់កុមារជនជាតិដើមភាគតិច ក្នុងខេត្តរតនគិរី | អង្គការភ្លែនអន្តរជាតិប៊ែលហ្ស៊ិក ភ្លែនអន្តរជាតិកម្ពុជា |   | រតនគិរី |
| ៤ | គម្រោងបណ្ដុះបណ្ដាលជំនាញថែទាំកូនៗរបស់ឪពុកម្ដាយ | អង្គការអាយស៊ីអេស (ICS) |  | សៀមរាប |
| ៥ | គម្រោងពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់គ្រួសារ | អង្គការភ្លែនអន្តរជាតិអូស្ត្រាលី រដ្ឋាភិបាលអូស្ត្រាលី អង្គការភ្លែនអន្តរជាតិកម្ពុជា |        | សៀមរាប និងកំពង់ចាម |
| ៦ | គម្រោងបណ្ដុះបណ្ដាលវិជ្ជាជីវៈដល់យុវជនដែលបោះបង់ការសិក្សា | អង្គការភ្លែនអន្តរជាតិអូស្ត្រាលី រដ្ឋាភិបាលអូស្ត្រាលី អង្គការភ្លែនអន្តរជាតិកម្ពុជា |  | សៀមរាប កំពង់ចាម និង រតនគិរី |

## ២.៣. អភិក្រម និងវិធីសាស្ត្រក្នុងការអនុវត្តន៍ការងារ

ដើម្បីសម្រេចបាននូវគោលដៅ ផ្តល់ឱ្យកុមារទទួលបាននូវការអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយ សមាគមគ្រួសារយើងបានបន្តអនុវត្តតាមអភិក្រម និងវិធីសាស្ត្រទាំងបីរបស់ខ្លួន ដោយសម្របទៅតាមស្ថានភាពជាក់ស្តែង និងបរិបទរបស់គម្រោងនីមួយៗ។

### ២.៣.១. អភិក្រមសមាហរណកម្មកម្មវិធី

ការដាក់ឱ្យកម្មវិធីគាំពារ និងអភិវឌ្ឍន៍កុមារតូច ដំណើរការតែមួយគឺមិនគ្រប់គ្រាន់នោះទេ ពីព្រោះការអភិវឌ្ឍន៍កុមារ វាអាស្រ័យទៅលើស្ថានភាពជីវភាពរស់នៅ ស្ថានភាពសុខភាពរបស់គ្រួសារ ជំនឿទុកចិត្តពីឪពុកម្តាយ និងកត្តាផ្សេងទៀតជាច្រើន។ ដូច្នេះ គម្រោងរបស់សមាគមគ្រួសារយើងដែលទទួលបានការឧបត្ថម្ភថវិកាគ្រប់គ្រាន់ ត្រូវបានរៀបចំឡើងជាមួយនឹងការរួមបញ្ចូលនូវសមាសធាតុថ្មីមួយចំនួនរួមមានការងារសង្គមនិងការប្រឹក្សាយោបល់ ការលើកស្ទួយជីវភាពរស់នៅ និងការធ្វើឱ្យប្រសើរនូវលទ្ធភាពទទួលបានសេវាសុខភាពក្នុងមូលដ្ឋាន។ តាមរយៈការរួមបញ្ចូលសកម្មភាពថ្មីៗទាំងនេះ សមាគមគ្រួសារយើងអាចធ្វើសកម្មភាពបានច្រើន ហើយឆ្លើយតបកាន់តែសមស្រប និងប្រសើរជាងមុនដល់អ្នកទទួលផលរបស់ខ្លួន ព្រមទាំងរួមចំណែកផ្តល់ឱ្យកុមារនូវការអភិវឌ្ឍន៍ភាសា បញ្ញា រាងកាយ និងសញ្ជេតនាសង្គម។

### ២.៣.២. ភាពជាដៃគូការងារ

សមាគមគ្រួសារយើង បានផ្សារភ្ជាប់បណ្តាញជាមួយនឹងស្ថាប័នពាក់ព័ន្ធពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ។ ជាងនេះទៅទៀតគ្រួសារយើងគឺជាប្រធានបណ្តាញអប់រំកុមារតូចនៅកម្ពុជានិងជាសមាជិកបណ្តាញថ្នាក់តំបន់ (ARNEC) ដែលមានសមាជិកចំនួន៩ ប្រទេស។ សមាគមគ្រួសារយើងបានចាត់ទុកគ្រួសារក្រីក្រ និងជនងាយរងគ្រោះបំផុតជាដៃគូយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសហគមន៍ ដោយពង្រឹងសមត្ថភាពឱ្យពួកគេយល់ពីសិទ្ធិអំណាចរបស់ពួកគេ ព្រមទាំងលើកទឹកចិត្តឱ្យពួកគេចេះ កសាងជាបណ្តាញ (ឬជាក្រុម) ដោយផ្តល់លទ្ធភាពឱ្យពួកគេអាចកៀងគរធនធាន ដែលមានស្រាប់នៅក្នុងសហគមន៍សម្រាប់ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។

### ២.៣.៣. សកម្មភាពយកសិទ្ធិមនុស្សជាមូលដ្ឋានក្នុងការអភិវឌ្ឍសហគមន៍

សមាគមគ្រួសារយើង បានសម្រេចចិត្តធ្វើអន្តរាគមន៍ដល់សហគមន៍ទាំងមូល ដោយយកចិត្តទុកដាក់លើ តម្រូវការជាមូលដ្ឋានរបស់គ្រួសារ និងសហគមន៍ ក្នុងទិសដៅជួយពង្រឹងទំនាក់ទំនង និងបង្កើតទម្លាប់ជួយគ្នារវាងប្រជាជនក្នុងភូមិ ព្រមទាំងលើកកម្ពស់ការចូលរួមរបស់គ្រួសារដៃគូនៅក្នុងសង្គម ស្ថានភាពរបស់គ្រួសារដៃគូនឹងអាចកែលម្អបានល្អប្រសើរ ហើយរក្សាស្ថេរភាពនេះបាន លុះត្រាតែសហគមន៍របស់ពួកគេទាំងមូលមានការអភិវឌ្ឍន៍ចម្រុះប្រកបដោយនិរន្តរភាព។ លើសពីនេះទៀត វាជាការសំខាន់ណាស់ដែលសកម្មភាពអភិវឌ្ឍមួយមានទិសដៅ ដើម្បីផ្លាស់ប្តូរស្ថានភាពគ្រួសារក្រីក្រឱ្យប្រសើរឡើង ហើយចាក់ឫសគល់រឹងមាំនៅក្នុងសហគមន៍ដែលកំពុងមានការអភិវឌ្ឍន៍យ៉ាងសកម្ម។

## ៣. តំបន់ប្រតិបត្តិការនិងអ្នកទទួលផលក្នុងឆ្នាំ២០១៤

(សូមមើលឧបសម្ព័ន្ធទី១និងទី២)




## <u>កំណត់សម្គាល់</u>

គ្រួសារយើង KROUSAR YOEUNG តំបន់ការងាររបស់សមាគមគ្រួសារយើង



ជាបណ្តាខេត្តដែលសមាគមគ្រួសារយើងបានបណ្តុះបណ្តាលគ្រូមត្តេយ្យសហគមន៍



## ៤.សកម្មភាពសំខាន់ៗក្នុងឆ្នាំ២០១៤

## ៤.១.ការងារអភិវឌ្ឍកុមារតូច និងលើកកម្ពស់សិទ្ធិកុមារ







### ៤.១.១.បង្កើតសាលាមត្តេយ្យសហគមន៍ប្រកបដោយគុណភាព និងនិរន្តរភាព

សាលាមត្តេយ្យសហគមន៍ជាប្រព័ន្ធឆ្លាស់មួយបំពេញឱ្យសាលាមត្តេយ្យរដ្ឋ ដែលមាននៅក្នុងទីប្រជុំជន។ ដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយរបស់កុមារ សមាគមគ្រួសារយើងបានបន្តបង្កើតសាលាមត្តេយ្យសហគមន៍ទាំងក្នុងតំបន់ជាយក្រុងភ្នំពេញ ខេត្តដែលជាប់ក្រុងភ្នំពេញ (ខេត្តកណ្តាល ខេត្តតាកែវ)ទាំងខេត្តនៅតំបន់ដាច់ស្រយាលនៅខេត្តរតនគីរី។

ឆ្នាំនេះយើងបានបង្កើតសាលាមត្តេយ្យសរុបចំនួន២២ សាលាក្នុងនោះមានសាងសង់ថ្មីចំនួន០៣សាលានៅខេត្តកណ្តាល ចំនួន១៥សាលានៅខេត្តរតនគីរី និងជួសជុល០៤សាលានៅខេត្តតាកែវ។ សាលាទាំងអស់សុទ្ធតែបានបំពាក់ល្បែងក្រៅថ្នាក់និងល្បែងគរុកោសល្យ ជាពិសេសគ្រួសារយើងបានបណ្តុះបណ្តាលគ្រូមត្តេយ្យសរុបចំនួន៤២នាក់ (១៩នាក់នៅភ្នំពេញ និង២៣នាក់នៅខេត្តរតនគីរី) ព្រមទាំងបណ្តុះបណ្តាលនៅនឹងកន្លែងរាល់ខែ ដើម្បីធានាការដឹកនាំសកម្មភាពជាមួយកុមារបំពេញការអភិវឌ្ឍន៍ រាងកាយ បញ្ញា ភាសា សញ្ចេតនាសង្គមរបស់កុមារប្រកបដោយគុណភាព និងធានានិរន្តភាព ព្រមទាំងស្វយ័តភាពរបស់សាលា គ្រួសារយើងបានបណ្តុះបណ្តាលគណៈគណៈកម្មការចំនួន៧៨ ស្រី២១នៅតំបន់ជាយក្រុងនិង១៨ស្រី១០នៅខេត្តរតនគីរី។ ឱ្យពួកអាចគ្រប់គ្រងសាលាកសាងមូលដ្ឋានសម្ភារៈ ការរកមូលនិធិឱ្យគ្រូ ការជួសជុលល្បែងគរុកោសល្យ ល្បែងក្រៅថ្នាក់ និងអាហារសម្រន់របស់កុមារ។ ការបណ្តុះបណ្តាលគ្រូឆ្នាំនេះមានពីរម៉ូឌុល (ម៉ូឌុល១ សម្រាប់ប្រធានក្រុមឪពុកម្តាយ និងម៉ូឌុល២សម្រាប់គ្រូមត្តេយ្យសហគម)។ បន្ទាប់ពីបណ្តុះបណ្តាលយើងបានចុះទៅប្រឹក្សា និងកែលម្អ បំប៉នដល់កន្លែងរៀងរាល់ខែ។



## ស្ថិតិសាលាសាងសង់និងជួសជុលឆ្នាំសិក្សា២០១៣-២០១៤
## (សូមមើលឧបសម្ព័ន្ធទី៣)

គ្រួសារយើងបាន ធ្វើសិក្ខាសាលាស្តីពីការស្វែងរកមូលនិធិជាមួយគណៈកម្មការ និងក្រុមប្រឹក្សាឃុំ សរុបចំនួន១០៦ ស្រី៣៦នៅតំបន់ជាយក្រុង ខេត្តកណ្តាល ខេត្តតាកែវ និងធ្វើសិក្ខាសាលាឆ្លុះបញ្ចាំងលើដំណើរការសាលា ស្វែងរកការគាំទ្រ និងធ្វើផែនការឆ្នាំសិក្សាថ្មី២០១៤-២០១៥នៅខេត្តរតនគីរី។

ជាលទ្ធផល នៅតំបន់នីមួយៗដំណើរការឆ្ពោះទៅរកនិរន្តភាពលេចចេញជាពន្លកហើយ។ គណៈកម្មការក្រុមប្រឹក្សាឃុំ និងគណៈកម្មការសាលាប្រឹងប្រែងតស៊ូមតិដាក់បញ្ចូលប្រាក់ឧបត្ថមគ្រូទៅក្នុងចំណាយអភិវឌ្ឍឃុំ បានរកថវិកាសម្រាប់ផ្គត់ផ្គង់ឱ្យគ្រូបាន២០០០០០រៀលស្មើនឹង៥០ដុល្លាក្នុង១ខែ រកចំណូលពីវត្តអារាម និងប្រភពផ្សេងៗទៀតសម្រាប់អាហារកុមារ ជួសជុលមូលដ្ឋានសម្ភារ ល្បែងគរុកោសល្យ ល្បែងក្រៅថ្នាក់ និងសម្ភារអនាម័យ។ រីឯខេត្តរតនគីរីជាកិច្ចការថ្មីសម្រាប់ពួកគាត់ តែពួកគាត់កំពុងរៀនសូត្រ និងធ្វើផែនការដាក់បញ្ចូលថវិកាចំណាយសម្រាប់ឧបត្ថម្ភគ្រូទៅក្នុងផែនការវិនិយោគឃុំរបស់គាត់។

សមាគមគ្រួសាយើងបានធ្វើយុទ្ធនាការប្រមូលកុមារចូលរៀន នៅគ្រប់តំបន់ការងារ។ ក្នុងឱកាសនោះមានវត្តមានរបស់ ការិយាល័យអប់រំយុវជន និងកីឡាស្រុក បុគ្គលិកសមាគមគ្រួសារយើង មេឃុំ ក្រុមប្រឹក្សាឃុំ មេភូមិ ប្រជាពលរដ្ឋ គណៈកម្មការទ្រទ្រង់សាលា អ្នកគ្រូមត្តេយ្យស្ម័គ្រចិត្ត កុមារមត្តេយ្យ កុមារបឋម និងចាស់ព្រឹទ្ធាចារ្យ។ នីតិវិធីនៃការធ្វើ មាន ទី១ជាការប្រជុំ ដង្ហែជាក្បួនដោយមានឧគ្ឃោសនស័ព្ទ មានហែរបដាតាមផ្លូវ និងបិទបដាតាមផ្ទះ ចុះជួបតាមផ្ទះ ដែលមានអ្នកចូលរួមសរុបចំនួន៤,៩៩៤នាក់ ស្រី២,៦២៣នាក់ ។

បច្ចុប្បន្ន សាលាមត្តេយ្យសហគមន៍មិនទាន់ស្វយ័តចំនួន៣៨ កំពុងស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់សមាគមគ្រួសារយើង។ រីឯសាលាមត្តេយ្យចំនួន ៦២ ផ្សេងទៀត (ទោះបីជាស្វយ័តក៏ដោយ) ក៏ទទួលបានការត្រួតពិនិត្យជាទៀងទាត់ពីបុគ្គលិកសមាគមគ្រួសារយើងផងដែរ។






## ស្ថិតិកុមារអាយុ៣-៥ ឆ្នាំ ចូលរៀននៅសាលាមត្តេយ្យសហគមន៍របស់សមាគមគ្រួសារយើងក្នុងឆ្នាំសិក្សា ២០១៣-២០១៤ ដោយធៀបនឹងកុមារក្នុងភូមិសរុប



## ស្ថិតិសាលាស្វ័យភាព( សូមមើលឧបសម្ព័ន្ធទី៤ )
## ស្ថិតិកុមារចូលរៀននៅសាលាមត្តេយ្យសហគមក្នុងឆ្នាំសិក្សា២០១៣-២០១៤ ( សូមមើលឧបសម្ព័ន្ធទី៥ )





### បញ្ហាប្រឈម

- គណៈកម្មការទ្រទ្រង់សាលាមត្តេយ្យ និងក្រុមប្រឹក្សាឃុំ នៅពុំទាន់មានសមត្ថភាពពេញលេញសម្រាប់គាំទ្រ ដំណើរការរបស់សាលាមត្តេយ្យ (ក្នុងការកៀរគរធន ធានក្នុងសហគមន៍ និងការស្វែងរកការគាំទ្រពីរ ដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាផ្សេងៗ ជាពិសេស បញ្ហាប្រាក់ខែគ្រូទាប។
- ប្រាក់ខែគ្រូមិនសមស្របទៅតាមតម្រូវការជីវភាព

### ដំណោះស្រាយ

- សមាគមគ្រួសារយើងបន្តពង្រឹងសមត្ថភាពរបស់គណៈ កម្មការទ្រទ្រង់សាលាមត្តេយ្យសហគមន៍ និងក្រុម ប្រឹក្សាឃុំក្នុងការកៀរគរធនធានពីសហគមន៍ (សម្រាប់ គាំទ្រការ ជួសជុលសាលា ការផលិតល្បែងសម្រាប់ កុមារ និង ផ្តល់ ប្រាក់ខែគ្រូ) និងអញ្ជើញមន្ត្រីទីចាត់ការ ផែនការវិនិយោគ របស់សាលារាជធានី-ខេត្ត ដើម្បីជួយ បណ្តុះ បណ្តាលក្រុម ប្រឹក្សាឃុំ ដោយដាក់បញ្ចូល ការងារ គាំពារនិងអភិវឌ្ឍន៍ កុមារតូច ទៅក្នុងផែនការ វិនិយោគឃុំ ដើម្បីដោះស្រាយបញ្ហាប្រាក់ខែគ្រូទាប ដែលជាបញ្ហា ប្រឈមចម្បងរបស់ សាលា មត្តេយ្យសហគមន៍។

### ចំណុចខ្លាំង

- សមាគមគ្រួសារយើង មានជំនាញយ៉ាងច្បាស់លាស់ ក្នុងការងារបង្កើត និងបណ្តុះបណ្តាលគណៈកម្មការ ទ្រទ្រង់សាលាមត្តេយ្យសហគមន៍ បណ្តុះបណ្តាលអ្នក គ្រូ ព្រមទាំងមានកិច្ចសហការល្អ និងរឹងមាំពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ ក្នុងកិច្ចការ គាំពារ និងអភិវឌ្ឍន៍ កុមារតូច។
- កិច្ចសហការយ៉ាងជិតស្និតជាមួយទីចាត់ការផែនការ វិនិយោគខេត្តក្នុងការចុះសហការពន្យល់ដល់មេឃុំ ក្រុមប្រឹក្សាឃុំ និងគណៈកម្មការដោយការដាក់បញ្ចូល គ្រូមត្តេយ្យសហគមន៍ទៅជាមន្ត្រីជាប់កិច្ចសន្យារបស់ ឃុំ។

### មេរៀនបទពិសោធន៍

- ភាពជោគជ័យក្នុងការបង្កើតសាសាមត្តេយ្យ សហគមន៍ គឺពឹងផ្អែកលើការចូលរួម និងការធ្វើ សេចក្តីសម្រេចចិត្តប្រកបដោយសុភវិនិច្ឆ័យរបស់ ការិយាល័យអប់រំ យុវជន និងកីឡាស្រុក និង មេឃុំ គណៈកម្មការទ្រទ្រង់សាលា ឪពុកម្តាយកុមារ ព្រម ទាំងភាពសកម្មប្រកបដោយជំនាញរបស់គ្រូ។

## ៤.១.២. ការខារអប់រំរបស់ឪពុកម្តាយចំពោះកូនៗ

ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍កុមារតូចឱ្យកាន់តែប្រសើរឡើង គ្រួសារយើងបានអនុវត្តនូវសកម្មភាពដ៏សំខាន់មួយ គឺពង្រឹងសមត្ថភាពរបស់ឪពុកម្តាយក្នុងការថែទាំកូន(ជាពិសេសកុមារអាយុ0ដល់៦ឆ្នាំ) ឱ្យមានសុខភាពល្អ និងរស់នៅក្នុងបរិស្ថានមួយប្រកបដោយសុខុមាលភាព ជំរុញឱ្យមានការលូតលាស់ និងការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ។ សកម្មភាពចម្បងនៃការងារនេះ គឺការរៀបចំកិច្ចប្រជុំក្រុមឪពុកម្តាយ (១ដងក្នុង១ខែ) ដែលដឹកនាំដោយអ្នកសម្របសម្រួល (ជ្រើសរើស ដោយប្រជាជនក្នុងភូមិ មេភូមិ ក្រុមប្រឹក្សាឃុំ និងបណ្តុះបណ្តាលដោយសមាគមគ្រួសារយើង និងផ្តោតទៅលើប្រធានបទសំខាន់ៗ ៨ ព្រមទាំងគន្លឹះទាំង១២សម្រាប់គ្រួសាររុង្គរឿង។ ការរៀបចំការប្រជុំក្រុមឪពុកម្តាយនេះបានបង្កើតបរិយាកាសរីករាយព្រមទាំង ផ្តល់ឱកាសឱ្យឪពុកម្តាយកុមារបានជួបជុំគ្នាក្នុងការចែករំលែកបទពិសោធន៍ល្អៗពាក់ព័ន្ធនឹងការថែទាំ អប់រំ ជំរុញការអភិវឌ្ឍន៍របស់កុមារ ដែលប្រការនេះនឹងរួមចំណែកផ្លាស់ប្តូរជាវិជ្ជមាន និងកសាងទម្លាប់ល្អ ចេះជួយគ្នាទៅវិញទៅមកក្នុងសហគមន៍របស់ពួកគេ ជាពិសេសនៅក្នុងការបំពេញតួនាទីជាឪពុកម្តាយ។

នៅក្នុងឆ្នាំ២០១៤ នេះ សកម្មភាពគាំទ្រការងារអប់រំរបស់ឪពុកម្តាយចំពោះកូនៗបានគ្របដណ្តប់ក្នុងរាជធានី-ខេត្តចំនួន៦៖ តំបន់ជាយរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តកណ្តាល ខេត្តតាកែវនិងខេត្តរតនគិរី ដោយយើងសម្រេចបាននូវលទ្ធផលសំខាន់ៗដូចខាងក្រោម៖

តាមរយៈកិច្ចប្រជុំក្រុមឪពុកម្តាយប្រចាំខែ ក្រុមឪពុកម្តាយទាំងអស់បានយល់ដឹងច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនក្នុងនាមជាឪពុកម្តាយ ទទួលបានចំណេះដឹងពាក់ព័ន្ធនឹងការថែទាំកូនៗ (តាមរយៈប្រធានបទទាំង ៨) និងបានផ្លាស់ប្តូរទម្លាប់ក្នុងការថែទាំ និងអភិវឌ្ឍន៍កូនៗ ចេះជ្រើសរើសយកវិធីសាស្ត្រថ្មីៗក្នុងការចិញ្ចឹមកូន និងជំរុញការអភិវឌ្ឍពេញលេញដល់កូន ។ តាមរយៈការវាយតម្លៃរបស់ក្រុមការងារ ឪពុកម្តាយភាគច្រើនផ្លាស់ប្តូរអាកប្បកិរិយាជាវិជ្ជមានក្នុងការថែរក្សាកូនដូចជា៖ផ្នែកអនាម័យ និងការថែរក្សាខ្លួនប្រាណ (៧៨.១៧%) ផ្នែករៀបចំបរិស្ថានសុវត្ថិភាពដល់កូនៗ (៨២%) ផ្នែកអាហារូបត្ថម្ភនិងសុខភាព (៧៨.១៧%) ក្តីស្រលាញ់ឪពុកម្តាយចំពោះកូន(៨0%) ជម្រុញការអភិវឌ្ឍន៍ភាសា សតិបញ្ញាកុមារឱ្យបានល្អ (៨0%) ការគ្រប់គ្រងអាកប្បកិរិយាកូន (៧៣.២%) ផ្នែកការធ្វើជាឪពុកល្អ ម្តាយល្អ (៧៨.១៧%) ផ្នែកការធ្វើជាឪពុកម្តាយកូនវ័យជំទង់ (៧៥.៥0%)។ លើសពីនេះទៀត ស្ត្រីមានផ្ទៃពោះចេះយកចិត្តទុកដាក់ក្នុង ការថែរក្សាគភ៌ដោយទៅពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាពជាទៀងទាត់។ ដោយឡែកខេត្តរតនគិរី ការប្រជុំក្រុមឪពុកម្តាយនៅជួបបញ្ហាទៅឡើយ តែយើងខិតខំកែលម្អស្ថានភាពឱ្យបានល្អប្រសើរឡើងនៅក្នុងឆ្នាំ២០១៥នេះ។





| ល.រ | ខេត្តគោលដៅ | ភាគរយនៃឪពុកម្តាយដែលមានការផ្លាស់ប្តូរអាកប្បកិរិយាជាវិជ្ជមានក្នុងការថែរក្សាកូន | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | អនាម័យ និងការថែរក្សាខ្លួនប្រាណ | អាហារូបត្ថម្ភ និងសុខភាព | បរិស្ថានសុវត្ថិភាពដល់កូនៗ | ការអភិវឌ្ឍន៍កុមារ | ក្តីស្រលាញ់ឪពុកម្តាយចំពោះកូន | ការគ្រប់គ្រងអាកប្បកិរិយាកូន | ការធ្វើជាឪពុកល្អ ម្តាយល្អ | ការធ្វើជាឪពុកម្តាយកូនវ័យជំទង់ |
| ១ | ភ្នំពេញ | ៧៥% | ៧៥% | ៨០% | ៨៥% | ៧៥% | ៧៥% | ៧៥% | ៧៥% |
| ២ | តាកែវ | ៧៥% | ៨០% | ៨៥% | ៨០% | ៨០% | ៨០% | ៨០% | ៨០% |
| ៣ | កណ្តាល | ៨៥% | ៨៥% | ៨៥% | ៨៥% | ៨០% | ៧៥% | ៨០% | ៧៥% |
| ៤ | សៀមរាប | ៨៨% | ៨៩% | ៨៩% | ៨៥% | ៩៥% | ៨០% | ៩០% | ៨៣% |
| ៥ | កំពង់ចាម | ៨៦% | ៨៤% | ៨៦% | ៨៧% | ៩៤% | ៨២% | ៨៨ % | ៨៤% |
| ៦ | រតនគីរី | ៦០% | ៥៦% | ៦៧% | ៥៨% | ៥៦% | ៥៦% | ៥៦% | ៥៦% |
| មធ្យមភាគ | | **៧៨,១៧%** | **៧៨,១៧%** | **៨២%** | **៨០%** | **៨០%** | **៧៣.២%** | **៧៨,១៧%** | **៧៥,៥០%** |

កុមារជាកោសិកាដ៏មានសក្តានុពលរបស់ឪពុកម្តាយ ពួកគាត់តែងតែចាត់ទុកកូនរបស់ខ្លួនជាកែវភ្នែក ពួកគាត់ចង់ឃើញកូនមានអនាគតល្អ។ ពាក្យស្លោករបស់វីរៈបុរសខ្មែរបានចារថា«កូនសោតរឹងឆ្អងត្បិតតែឪពុកម្តាយ»។ ឪពុកម្តាយ មានតួនាទីដ៏សំខាន់ណាស់ ដែលត្រូវបំពេញចំពោះមុខកូនដែលស្ថិតនៅក្នុងដំណាក់កាលពីចាប់កំណើតក្នុងផ្ទៃម្តាយរហូតអាយុ ៦ឆ្នាំដែលជាដំណាក់កាលដ៏សំខាន់ពាក់ព័ន្ធ នឹងការអភិវឌ្ឍរបស់កូន។ បរិបទនៅកម្ពុជាយើងឪពុកម្តាយនៅតែបន្តការទទួលខុសត្រូវក្នុង ការថែទាំអប់រំកូនរហូតកូនពេញវ័យ។

តែការគិតគូរដល់សមត្ថភាពរបស់ឪពុកម្តាយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់គាត់ត្រូវបានគេមើលរំលង។ ចំណុចនេះហើយជាហេតុផលមួយដែលសមាគមគ្រួសារយើងចាត់ទុកសកម្មភាពនេះជាចំណុចស្នូលចំបងមិនអាច ខ្វះបាន បើចង់អភិវឌ្ឍន៍កុមារចាំបាច់គិតដល់សមត្ថភាព លទ្ធភាព និងឱកាសរបស់ឪពុកម្តាយ។

# ស្ថិតិក្រុម សមាជិកក្រុមនិងអ្នកឧទ្ទេស/ឪពុកម្តាយស្នូល

| ល.រ | ខេត្ត គោលដៅ | ចំនួន ក្រុម | ចំនួនសមាជិក (សរុប/ស្រី) | ចំនួនអ្នក ឧទ្ទេស (សរុប/ស្រី) | ស្ថិតក្នុងក្របខ័ណ្ឌនៃគម្រោង |
|---|---|---|---|---|---|
| ១ | ភ្នំពេញ | ៤១ | ៦៥៣/៥៨២ | ១២ /១០ | *គម្រោងកសាងសមត្ថភាពរបស់ភាគីមិនមែនរដ្ឋដែលធ្វើការងារលើកកម្ពស់ការអប់រំកុមារតូចក្រៅប្រព័ន្ធនៅក្នុងតំបន់ជាយរាជធានីភ្នំពេញ* |
| ២ | តាកែវ | ៣០ | ៣៩០/៣៣៨ | ១៣ /៧ | |
| ៣ | កណ្តាល | ៦៥ | ៨៤៣/៧៤៧ | ១៧ /៨ | |
| ៤ | សៀមរាប | ២៥ | ១៥៨៤/១២៨៤ | 0 | គម្រោងបណ្តុះបណ្តាលជំនាញថែទាំកូនៗរបស់ឪពុកម្តាយ |
| ៥ | កំពង់ចាម | ១៩ | ៥៥៥/៣៩៥ | ៣៣/១៩ | គម្រោងពង្រឹងភាពជាម្ចាស់ការ និងការទទួលខុសត្រូវរបស់គ្រួសារ |
| ៦ | រតនគីរី | ២៥៤ | ១៣៣១/៣៦៨ | ៨៨/៤១ | *គម្រោងការគាំពារនិងការអភិវឌ្ឍន៍កុមារតូច សម្រាប់កុមារជនជាតិភាគតិច ក្នុងខេត្តរតនគីរី* |
| **សរុប** | | **៣៩៣** | **៥៣៥៦/៣៧១៤** | **១៦៣/៨៥** | |

- នៅក្នុងក្របខ័ណ្ឌនៃ*គម្រោងពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់គ្រួសារ*ដែលកំពុងអនុវត្តក្នុងខេត្តសៀមរាប និងកំពង់ចាម សមាគមគ្រួសារយើងបានបញ្ជ្រាបការគាំទ្រការងារអប់រំរបស់ឪពុកម្តាយចំពោះកូនៗ នេះ តាមរយៈសកម្មភាពសំខាន់ៗ (ការប្រឹក្សាយោបល់ ការប្រជុំណែនាំស្តីពីការអនុវត្តន៍អនាម័យល្អប្រចាំភូមិ វគ្គបណ្តុះបណ្តាលជំនាញកសិកម្ម និងកិច្ចប្រជុំផ្សេងៗទៀត) ដល់គ្រួសារដៃគូចំនួន ១,៨៩១ គ្រួសារ និងគ្រួសារមិនមែនដៃគូចំនួន១,៦០៨ គ្រួសារ ។ តាមរយៈការវាយតម្លៃរបស់ក្រុមការងារ ៧៣,៥% នៃគ្រួសារទាំងអស់នោះ មានភាពប្រសើរឡើងនៅក្នុងជំនាញថែទាំកូន។

**<u>បញ្ហាប្រឈម</u>**

- ប្រជាជនមមារញឹកជាមួយការងាររកប្រាក់ចំណូល ដែលជាហេតុធ្វើឱ្យក្រុមការងារពិបាកណាត់ជួបពួកគាត់ ជាពិសេសបុរសជាឪពុក។
- ក្នុងខេត្តរតនគីរីវិញ ពុំសូវមានធនធានមនុស្ស (ចេះអាន និងសរសេរអក្សរខ្មែរ)ដើម្បីធ្វើជាប្រធានក្រុមស្នូលឪពុកម្តាយ។
- បុគ្គលិកថ្មីខ្វះជំនាញ គ្មានឧបនិស្ស័យ

**<u>ដំណោះស្រាយ</u>**

- អ្នកឧទ្ទេសដាក់ផែនការឱ្យចំពេលដែលពួកគាត់ទំនេរពីការងារដូចជាថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ឬពេលល្ងាចជាដើម និងចុះជួបពិភាក្សាជាមួយសមាជិកក្រុមឪពុកម្តាយដល់ផ្ទះ។
- យើងត្រូវជ្រើសរើសអ្នកដែលមានចំណាប់អារម្មណ៍ និងបណ្តុះបណ្តាលបង្កើនសមត្ថភាពបន្ថែម។

**<u>ចំណុចខ្លាំង</u>**

- បុគ្គលិកសមាគមគ្រួសារយើង មានជំនាញក្នុងការអប់រំឪពុកម្តាយច្បាស់លាស់ និងមានបទពិសោធន៍ក្នុងការកៀងគរប្រជាជនក្នុងសហគមន៍ ជាពិសេសឪពុកម្តាយ ឱ្យចូលរួមក្នុងសកម្មភាព។
- សមាគមគ្រួសារយើងសហការនិងមានទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋាន និងទទួលបានការគាំទ្រពីពួកគាត់ក្នុងការអនុវត្តន៍សកម្មភាពនានារបស់គម្រោងនៅថ្នាក់មូលដ្ឋាន។
- អ្នកសម្របសម្រួលចូលរួមធ្វើសកម្មភាពយ៉ាងផុសផុលក្នុងការប្រជុំផ្សព្វផ្សាយតាមប្រធាននីមួយៗ (ប្រធានបទទាំង៨ និងគន្លឹះទាំង ១២)។

**<u>មេរៀនបទពិសោធន៍</u>**

- កម្មវិធីដំណើរការបានល្អ ត្រូវមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន និងការិយាល័យអប់រំយុវជន និងកីឡាស្រុក កិច្ចការនារីស្រុក ឃុំ ក្នុងការផ្សព្វផ្សាយ ចងក្រងក្រុមឪពុកម្តាយ និងជំរុញដល់ការអនុវត្តន៍នៅតាមផ្ទះ ។
- អ្នកសម្របសម្រួលដែលនឹងជ្រើសរើសត្រូវតែជាមនុស្សដែលសកម្ម មានភាពឧស្សាហ៍ព្យាយាម និងមានមនសិការវិជ្ជាជីវៈខ្ពស់ក្នុងការដឹកនាំក្រុមប្រជុំ តាមដានជំរុញការអនុវត្តន៍របស់សមាជិកក្រុម និងវាយតម្លៃការអនុវត្តន៍ឱ្យបានម៉ត់ចត់ ។
- ក្រុមការងារត្រូវជ្រើសរើសប្រធានបទ និងកំណត់ពេលប្រជុំស្របតាមស្ថានភាពជាក់ស្តែង ទើបគម្រោងបានសម្រេចជោគជ័យ ។
- រៀបចំឱ្យមានអ្នកសម្របសម្រួលនៅតាមភូមិ/តាមមូលដ្ឋានធានានិរន្តរភាពរបស់គម្រោង



## ៤.១.៣. មជ្ឈមណ្ឌលធនធានកុមារតូច

ដោយមានការគាំទ្រថវិកាពីសហគមន៍អឺរ៉ុប (EU) និងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអង្គការកុមារនិងអភិវឌ្ឍន៍ សមាគមគ្រួសារយើងបានបង្កើតមជ្ឈមណ្ឌលធនធានកុមារតូច ដែលមានឯកទេសខាងការងារគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅក្នុងឆ្នាំ២០១០។ គោលបំណងនៃការបង្កើតមជ្ឈមណ្ឌលនេះ គឺដើម្បីចងក្រងឯកសារ និងបទពិសោធន៍របស់សមាគមគ្រួសារយើងក្នុងវិស័យអប់រំកុមារតូចទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ព្រមទាំងបង្កើតឯកសារថ្មីៗ (រួមមាន រឿងនិទានវីដេអូគុរុកោសល្យសម្រាប់បណ្តុះបណ្តាល វីដេអូផ្សព្វផ្សាយពីសារសំខាន់នៃការថែទាំ អប់រំនិងអភិវឌ្ឍកុមារតូចនៅក្នុងសហគមន៍ ចម្រៀង ព្រឹត្តិបត្រព័ត៌មាន និងឯកសារថ្មីៗផ្នែកអប់រំកុមារតូច) សម្រាប់ធ្វើការផ្សព្វផ្សាយដល់តួអង្គផ្សេងៗ (ទាំងនៅក្នុងផ្នែករដ្ឋ និងឯកជន) ដែលកំពុងធ្វើការងារក្នុងវិស័យគាំពារ និងអភិវឌ្ឍន៍កុមារតូច។ គម្រោងមជ្ឈមណ្ឌលធនធានកុមារតូចមានសកម្មភាពចម្បងៗចំនួន៣គឺៈ

### -ការងារបណ្តុះបណ្តាល

សមាគមគ្រួសារយើង មានបុគ្គលិកជំនាញលើបច្ចេកទេស និងបទពិសោធន៍ក្នុងការងារគាំពារ និងអភិវឌ្ឍន៍កុមារតូច ព្រមទាំងបានផ្តល់សេវាកម្មបណ្តុះបណ្តាលជំនាញដល់ភាគីពាក់ព័ន្ធក្នុងវិស័យគាំពារ និងអភិវឌ្ឍន៍កុមារតូច និងដើម្បីចូលរួមអភិវឌ្ឍធនធានមនុស្សក្នុងវិស័យនេះឱ្យបានកាន់តែប្រសើរឡើង និង ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការសម្រេចបាននូវផែនការសកម្មភាពជាតិស្តីពីការគាំពារ និង អភិវឌ្ឍន៍កុមារតូច២០១៤-២០១៨ ។ ក្រោមកិច្ចសហការល្អជាមួយនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នាយកដ្ឋានអប់រំកុមារតូច របស់ក្រសួងអប់រំ យុវជន និងកីឡា សមាគមគ្រួសារយើង បានរៀបចំនូវវគ្គបណ្តុះបណ្តាលជំនាញគាំពារ និងអភិវឌ្ឍន៍កុមារតូច( បច្ចេកទេសគ្រូមត្តេយ្យ ការគាំទ្រការងារអប់រំរបស់ឪពុកម្តាយចំពោះកូនៗ ជំនាញប្រឹក្សាយោបល់ជាមួយអ្នកគាំទ្រ និង ល្បែងសេរី) ។ វគ្គបណ្តុះបណ្តាលជំនាញគាំពារ និងអភិវឌ្ឍន៍កុមារតូចនេះ គឺជាសេវាកម្មដែលសមាគមគ្រួសារយើង រៀបចំសម្រាប់ ផ្តល់ដល់អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន ដែលធ្វើការក្នុងវិស័យកុមារតូច ហើយក៏ជាសកម្មភាពមួយ ស្ថិតក្រោមក្របខ័ណ្ឌនៃគម្រោង *កសាងសមត្ថភាពរបស់ភាគីមិនមែនរដ្ឋ ដែលធ្វើការងារលើកកម្ពស់ការអប់រំកុមារតូចក្រៅប្រព័ន្ធនៅក្នុងតំបន់ជាយរាជធានីភ្នំពេញ* និងគម្រោង *មជ្ឈមណ្ឌលធនធានកុមារតូច* ។

ការរៀបចំវគ្គបណ្តុះបណ្តាលនេះ មានគោលបំណងពង្រឹងសមត្ថភាពបច្ចេកទេសគាំពារ និងអភិវឌ្ឍន៍កុមារតូច រួមមានសមត្ថភាពបង្រៀន និងថែរក្សាកុមារតូច សមត្ថភាពក្នុងការអនុវត្តន៍គម្រោង តាមដានដំណើរការគម្រោង និងដោះស្រាយបញ្ហាដែលគម្រោងជួបប្រទះ និងសមត្ថភាពក្នុងការទំនាក់ទំនង ដល់តួអង្គដែលធ្វើការងារក្នុងវិស័យនេះ។

តួអង្គដែលសំខាន់សម្រាប់វគ្គបណ្តុះបណ្តាលនេះ រួមមានគ្រូមត្តេយ្យស្ម័គ្រចិត្ត (វគ្គបណ្តុះបណ្តាលមាន៣ ម៉ូឌុល[1]) គណៈកម្មការទ្រទ្រង់សាលាមត្តេយ្យសហគមន៍ (វគ្គបណ្តុះបណ្តាលមាន៤ម៉ូឌុល) និង អ្នកឧទ្ទេសអប់រំឪពុក ម្តាយ (វគ្គបណ្តុះបណ្តាលមាន៨ប្រធានបទនិង១២គន្លឹះ)។

**វគ្គបណ្តុះបណ្តាលគ្រូមត្តេយ្យ**

វគ្គបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាត្រូវបានរៀបចំជាបីដំណាក់កាល មួយដំណាក់កាលមានរយៈពេល២៣ថ្ងៃ។ ចំពោះ ម៉ូឌុលទី១និងម៉ូឌុលទី២ គឺជាម៉ូឌុលដែលផ្តល់នូវការណែនាំនិងសិក្សា លម្អិតទាំងផ្នែកទ្រឹស្តី និងការអនុវត្តរួមទាំងកម្មវិធីសិក្សាផង។ ខ្លឹមសារសំខាន់ៗរបស់វគ្គនីមួយៗមានបង្ហាញដូចខាងក្រោម៖

**មេរៀនសម្រាប់វគ្គបណ្តុះបណ្តាលគ្រូមត្តេយ្យ**

១. គោលបំណង និង តួនាទីរបស់សាលាមត្តេយ្យ
២. សញ្ញាណមូលដ្ឋានស្តីពីការអភិវឌ្ឍន៍កុមារ
៣. ហត្ថកម្ម-គំនូស
៤ .ការអភិវឌ្ឍន៍បញ្ញា (គណិតវិទ្យានៅមត្តេយ្យ)
៥ .ចិត្តចលភាព
៦. បុរេសំណេរ
៧. តន្ត្រី និងចម្រៀង
៨. ទំនាក់ទំនងជាមួយមាតាបិតា និង កិច្ចសហការជាមួយ គណៈកម្មការ និង មនសិការវិជ្ជាជីវៈ
៩. សង្កេត/ទស្សនាសង្កេត(គរុកោសល្យបរិស្ថាន)/វិទ្យាសាស្ត្រ
១០ .ការអភិវឌ្ឍន៍ភាសា
១១ .កម្មវិធី និង កាលវិភាគ
១២ .អនាម័យ
១៣ .កុមារមជ្ឈមណ្ឌល/វិធីសាស្ត្រគ្រប់គ្រងក្រុម







- ដំណាក់កាលទី១៖ ការបណ្តុះបណ្តាលផ្តោតទៅលើមូលដ្ឋាននៃចិត្តគរុកោសល្យរបស់មេរៀននីមួយៗ
- ដំណាក់កាលទី២៖ ការបណ្តុះបណ្តាលយកចិត្តទុកដាក់លើការអនុវត្តជាក់ស្តែងដែលគ្រូជួបប្រទះនៅដំណាក់ការដំបូងនៃការរៀបចំសកម្មភាពនិងដឹកនាំសកម្មភាពរបស់គ្រូនៅឯសាលារបស់គាត់
- ដំណាក់កាលទី៣៖ គ្រូបង្ហាញពីការលំបាករបស់ពួកគាត់ អ្នកគ្រូឧទ្ទេសបង្ហាញដំណោះស្រាយ និង ផ្តល់ឱកាសឱ្យពួកគាត់ផ្លាស់ប្តូរបទពិសោធន៍ ដោយគ្រូ បានរៀបចំនិងដឹកនាំសកម្មភាពជាមួយកុមារនៅសាលាមត្តេយ្យរយៈពេល១ឆ្នាំកន្លងមក។

[1]ម៉ូឌុលនីមួយៗ មានវគ្គបណ្តុះបណ្តាលដាច់ដោយឡែកពីគ្នា។

## វគ្គបណ្តុះបណ្តាល លើការគាំទ្រការងារអប់រំរបស់ឪពុកម្តាយចំពោះកូនៗ

ការងារវគ្គបណ្តុះបណ្តាលសម្រាប់គ្រូឧទ្ទេសគឺជាវិធីមួយដែលមានប្រសិទ្ធិភាព និងប្រសិទ្ធផលក្នុងការកសាងសមត្ថភាពរបស់បុគ្គលិក ដើម្បីធ្វើការជាមួយឪពុកម្តាយនិង អ្នកមើលថែកុមារ។ វគ្គបណ្តុះបណ្តាលនេះ ផ្តោតទៅលើប្រធានបទនិងផ្តល់ដោយគ្រូបណ្តុះបណ្តាលដែលមានបទពិសោធន៍និងមានលក្ខណៈសម្បត្តិខ្ពស់ក្នុងការចែករំលែកចំណេះដឹង។

**<u>ប្រធានបទទាំង៨</u>**

ប្រធានបទទី១: ការថែរក្សាកុមារឱ្យមានសុខភាពល្អ:អនាម័យ និង ការថែទាំប្រចាំថ្ងៃ

ប្រធានបទទី២:ការថែរក្សាកុមារឱ្យមានសុខភាពល្អជានិច្ច: ការបំប៉នចំណីអាហារ

ប្រធានបទទី៣: បរិស្ថានមួយប្រកបដោយសុវត្ថិភាពអាចជួយបង្ការការរងរបួស: គ្រោះថ្នាក់ផ្សេងៗ និងការកេងប្រវ័ញ្ចបាន

ប្រធានបទទី៤: សេចក្តីស្នេហា និងការស្រឡាញ់:គឺជាតម្រូវការមួយដ៏ចម្បង

ប្រធានបទទី៥: ការជួយជំរុញឱ្យកុមារមានការអភិវឌ្ឍប្រសើរឡើង

ប្រធានបទទី៦: ការគ្រប់គ្រងអាកប្បកិរិយាឱ្យបានល្អប្រសើរ

ប្រធានបទទី៧: ទាំងឪពុកទាំងម្តាយ

ប្រធានបទទី៨: ការយល់ចិត្តនិងការធ្វើទំនាក់ទំនងឱ្យបានល្អគឺជាកាតព្វកិច្ចរបស់ឪពុកម្តាយនៅពេលកូនឈានចូលវ័យជំទង់





## វគ្គបណ្តុះបណ្តាល គណៈកម្មការទ្រទ្រង់សាលាមត្តេយ្យសហគមន៍

សមាសភាពគណៈកម្មការជាតួអង្គសំខាន់មួយ ក្នុងចំណោមតួអង្គទាំង៤ របស់សាលាមត្តេយ្យសហគមន៍ ដើម្បីឱ្យសាលាមត្តេយ្យមួយអាចដំណើរការបានលុះត្រាតែ គណៈកម្មការបានទទួលវគ្គបណ្តុះបណ្តាលដើម្បីពង្រីកនិងពង្រឹងសមត្ថភាពរបស់ពួកគាត់។ ខ្លឹមសារសំខាន់ៗក្នុងវគ្គបណ្តាលរួមមាន៖

# ស្ថិតិបណ្តុះបណ្តាលឆ្នាំ២០១៤

| អ្នកទទួលការបណ្តុះបណ្តាល | ២០១៤ | | |
|---|---|---|---|
| | សរុប | គ្រួសារយើង | អង្គការផ្សេងៗ |
| គ្រូមត្តេយ្យ | ៧៩ | ១៩ | ៦០ |
| គណៈកម្មការ ទ្រទ្រង់ សាលាមត្តេយ្យ | ៩៦ | ៩៦ | 0 |
| អ្នកឧទ្ទេស អប់រំឪពុក ម្តាយ/ប្រធានក្រុមស្នូល | ៤១ | ៤១ | 0 |
| សរុប | ២១៦ | ១៥៦ | ៦០ |

- គ្រូមត្តេយ្យសហគមន៍ចំនួន ៧៩នាក់ (ស្រី៧៨នាក់)យល់ដឹងពីតួនាទីរបស់ខ្លួន និងគោលគំនិតសំខាន់ៗនៃការអភិវឌ្ឍន៍កុមារបានកាន់តែប្រសើរ បានបង្កើនសមត្ថភាពខ្លួនក្នុងការបង្រៀនកុមារ ចេះផលិតល្បែងសម្រាប់កុមារ រក្សាអនាម័យបានល្អចំពោះកុមារ និងសហការជាមួយមាតាបិតាសិស្សបានល្អ។
- គណៈកម្មការទ្រទ្រង់សាលាមត្តេយ្យសហគមន៍ ចំនួន ៩៦នាក់ (ស្រី៣១នាក់) បានបង្កើនសមត្ថភាព និងឆន្ទៈរបស់ខ្លួនក្នុងការគ្រប់គ្រងដំណើរការសាលាមត្តេយ្យសហគមន៍ ធនាគារស្រូវ និងគម្រោងអាជីវកម្មបានល្អ ចេះធ្វើសំណើគម្រោង និងកៀរគរធនធានក្នុងសហគមន៍ ដើម្បីធានាចីរភាពនៃដំណើរការសាលាមត្តេយ្យសហគមន៍។
- អ្នកឧទ្ទេសចំនួន ៤១នាក់ ស្រី ២៥នាក់ បានបង្កើនការយល់ដឹងពីការអប់រំ សុខភាព អនាម័យ ការអភិវឌ្ឍន៍កុមារ ហើយមានសមត្ថភាពធ្វើការបណ្តុះបណ្តាលបន្តទៅដល់ក្រុមឪពុកម្តាយតាមតំបន់គោលដៅរបស់ខ្លួន។
- បច្ចុប្បន្ន សិក្ខាកាមទាំងអស់ កំពុងបំពេញភារកិច្ចតាមមុខងាររបស់ខ្លួន នៅតាមសាលាមត្តេយ្យសហគមន៍ និងតំបន់គោលដៅរៀងៗខ្លួន ហើយរួមគ្នាបង្កើតនូវបរិយាកាសអំណោយផលមួយ (ទាំងនៅក្នុងផ្ទះ និងនៅក្នុងថ្នាក់រៀន) សម្រាប់ការលូតលាស់ និងការអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយរបស់កុមារ។





**បញ្ហាប្រឈម**

- ការចុះឈ្មោះចូលរៀនពីបណ្ដាអង្គការដៃគូនានា មានភាពយឺតយ៉ាវ។
- កម្រិតវប្បធម៌របស់សិក្ខាកាមមិនស្មើគ្នា ដែលធ្វើឱ្យគ្រូឧទ្ទេសត្រូវចំណាយពេលច្រើនក្នុងការសម្របសម្រួល (ការសរសេរកិច្ចតែងការបង្រៀន ខ្លឹមសារមេរៀន) ។
- ការបណ្ដុះបណ្ដាលគ្រូនៅខេត្តរតនគិរីមានរយៈពេលខ្លី

**ដំណោះស្រាយ**

- បង្កើនប្រសិទ្ធភាពនៃការទំនាក់ទំនង តាមរយៈការផ្សព្វផ្សាយតាមរយៈអ៊ីម៉ែលនិងការទំនាក់ទំនងតាមទូរស័ព្ទ។
- ផ្ដល់ឱកាសឱ្យសិក្ខាកាមសរសេរកិច្ចតែងការខ្លីដែល ងាយមើលយល់ដោយខ្លួនឯង និងជួយបង្រៀនបន្ថែម។
- ចុះទៅបណ្ដុះបណ្ដាលនៅនឹងកន្លែងឱ្យបានញឹកញាប់

**ចំណុចខ្លាំង**

- កម្មវិធីបណ្ដុះបណ្ដាលមានការទទួលស្គាល់ពីនាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- សមាគមគ្រួសារយើង មានធនធាន (អ្នកឧទ្ទេស) ដែលមានទាំងជំនាញនិងបទពិសោធន៍ច្បាស់លាស់ក្នុងវិស័យគាំពារ និងអភិវឌ្ឍន៍កុមារតូច។
- សិក្ខាកាមដែលទទួលបានការបណ្ដុះបណ្ដាលហើយ អាចអនុវត្តសកម្មភាពដោយខ្លួនឯងបានល្អប្រសើរ។

**មេរៀនបទពិសោធន៍**

- ការរៀបចំទុកជាមុនសម្រាប់ការបណ្ដុះបណ្ដាល (សម្ភារ និងពេលវេលាបង្រៀនរបស់គ្រូ) របស់ក្រុមការងារ ជួយឱ្យការបណ្ដុះបណ្ដាលប្រព្រឹត្តទៅដោយជោគជ័យ។
- ការសហការជាមួយមន្ត្រីបច្ចេកទេសក្រសួងអប់រំ និងក្រសួងសុខាភិបាលបានបង្កើនគុណភាពការបណ្ដុះបណ្ដាលរបស់សមាគមគ្រួសារយើង។
- រាល់ការអនុវត្តជាក់ស្តែងរបស់សិក្ខាកាម ទាមទារឱ្យមានការផ្ដល់ព័ត៌មានត្រឡប់ពីសិក្ខាកាមផ្ទាល់ អ្នករួមក្រុម និងអ្នកចុះវាយតម្លៃ នោះនឹងធ្វើឱ្យពួកគេយល់ច្បាស់ពីចំណុចខ្លាំង និងចំណុចខ្សោយ ដើម្បីឈានទៅបន្តពង្រឹងចំណុចខ្លាំង និង កែលម្អចំណុចខ្វះខាត។

## -ការចងក្រងឯកសារ

### សកម្មភាពបណ្ណាល័យ

បណ្ណាល័យរបស់មជ្ឈមណ្ឌលធនធានកុមារតូចត្រូវបានបង្កើតឡើង ដោយផ្ទុកឯកសារជាច្រើនពាក់ព័ន្ធនឹងការគាំពារ និងអភិវឌ្ឍន៍កុមារតូច។ បច្ចុប្បន្ន បណ្ណាល័យមានឯកសារ (សៀវភៅ អត្ថបទ ស៊ីឌី ឌីវីឌី និងផ្ទាំងរូបភាព) ចំនួន១,២៩៩ចំណងជើង អត្ថបទអេឡិចត្រូនិកចំនួន១៤៩ចំណងជើង ល្បែងសម្រាប់កុមារចំនួន១២៥ ចំណងជើង និងរឿងនិទានសម្រាប់កុមារចំនួន៣៣៤ចំណងជើង ត្រូវបានរៀបចំបែងចែកចំណាត់ថ្នាក់តាមប្រព័ន្ធ Dewey Decimal Classification សម្រាប់បម្រើដល់អ្នកអាន។ ការប្រើប្រាស់សេវាបណ្ណាល័យរបស់មជ្ឈមណ្ឌលធនធានកុមារតូច មានការកើនឡើងជាលំដាប់។ ជាក់ស្តែងឆ្នាំនេះមានអ្នកប្រើប្រាស់សេវាបណ្ណាល័យចំនួន៣៧៦នាក់(អានសៀវភៅ ទស្សនាវីដេអូ សួររកប្រភេទឯកសារ) និង ៧៦ នាក់បានខ្ចីយក ទៅអាននៅផ្ទះ។

### ការកែលម្អ និង បង្កើតឯកសារថ្មី

ដើម្បីពង្រឹងសមត្ថភាពគាំពារ និងអភិវឌ្ឍន៍កុមារតូចរបស់តួអង្គពាក់ព័ន្ធនានា ក្រុមការងារគម្រោងបានសហការជាមួយក្រុមសម្របសម្រួលបច្ចេកទេស (ដែលមានសមាសភាពមកពីក្រសួងអប់រំ យុវជន និងកីឡា) ពិនិត្យ និងបង្កើត ព្រមទាំងចែកចាយឯកសារជាច្រើនដូចខាងក្រោម៖

- បង្កើតឯកសារអប់រំឪពុកម្តាយ(១២គន្លឹះ) និងឯកសារកុមារតូច សម្រាប់ជនជាតិដើមភាគតិចនៅខេត្តរតនគិរី។
- បង្កើតឯកសារវីដេអូសម្រាប់ជំនួយដល់ការបណ្តុះបណ្តាលគ្រូមត្តេយ្យ បានចំនួន៤គឺៈ
  - របៀបបង្រៀនគណិតវិទ្យា៖ វិស័យបរិមាណ និងចំនួន
  - របៀបបង្រៀនគណិតវិទ្យា៖ វិស័យរង្វាស់
  - របៀបបង្រៀនបុរេសំណេរ៖ បំណិនស្តាប់
  - របៀបបង្រៀនបុរេសំណេរ៖ ស្គាល់អក្សរមួយពេល
- ការបង្កើតឯកសារថ្មីស្តីពី ល្បែងសេរី ចិត្តចលភាពស្មៀមស្ងាត់ និង ទស្សនៈវិជ្ជានៅមត្តេយ្យសិក្សា ។ រាល់ ឯកសារដែលបានបង្កើតថ្មីនេះគឺយើងបានធ្វើតេស្តសាកល្បងជាមួយកុមារមត្តេយ្យគ្រប់កម្រិតទាំងអស់។ ចំពោះល្បែងសេរីគឺយើងបានដាក់ឱ្យដំណើរការកម្មវិធីនៅតាមសាលាចំនួន៩។
- ការធ្វើបច្ចុប្បន្នភាពឯកសារ៖ សៀវភៅគណិតវិទ្យានៅមត្តេយ្យសិក្សា និង សៀវភៅគំនូស និង ការត្រៀមកុមារឱ្យហាត់សរសេរផ្នែកមត្តេយ្យសិក្សាត្រូវបាន ធ្វើបច្ចុប្បន្នភាព ហើយនឹងប្រកាសផ្សព្វផ្សាយនៅខែមិថុនា ឆ្នាំ២០១៥ ដោយមានសមាសភាពគណៈកម្មការទាំងអស់ចូលរួម ព្រមទាំងសមាជិកបណ្តាញការងារគាំពារនិងអភិវឌ្ឍកុមារតូចចូលរួមផងដែរ។ សៀវភៅបានចេញប្រកាសឱ្យបោះពុម្ពប្រើទូទាំងប្រទេស ដោយឯកឧត្តមបណ្ឌិត ហង់ជួន ណារ៉ុង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡាចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥។

## ព្រឹត្តបត្រព័ត៌មានសម្រាប់មត្តេយ្យសិក្សា

បានបោះពុម្ព និងចែកចាយព្រឹត្តិបត្រព័ត៌មានមត្តេយ្យសិក្សា លេខ៦ លេខ៧ លេខ៨ និងលេខ៩ (២,១៨០ច្បាប់) ដល់គ្រូមត្តេយ្យសហគមន៍នៅក្នុង ២៣ រាជធានីខេត្ត នាយកដ្ឋានអប់រំកុមារតូច និងសាលាគរុកោសល្យមត្តេយ្យមជ្ឈិម សំដៅពង្រឹងសមត្ថភាពបង្រៀនរបស់គ្រូមត្តេយ្យសហគមន៍។

## ល្បែងសេរី

ក្នុងបណ្ដាប្រាំឆ្នាំដំបូងនៃជីវិតរបស់កុមារគឺជាដំណាក់កាលមួយសំខាន់ណាស់ ដែលទាមទារឱ្យមនុស្សចាស់ចេះរៀបចំនូវលក្ខខណ្ឌជាមូលដ្ឋានទាំងឡាយ សម្រាប់ជួយសម្រួលដល់ការហាត់រៀនរបស់ពួកគេទៅអនាគត។ ដើម្បីបំពេញនូវកាតព្វកិច្ចនេះ និងឆ្លើយតបទៅនឹង តម្រូវការចម្បងរបស់កុមារទូទាំងសកលលោកគឺ "ការលេង"ដែលជាកត្តារួមចំណែកដ៏សំខាន់ក្នុងការអភិវឌ្ឍរបស់កុមារនោះ សមាគមគ្រួសារយើង ដោយមានកិច្ចសហប្រតិបត្តិការជាមួយអង្គការកុមារនិងការអភិវឌ្ឍ និងអង្គការផ្លូវដើររបស់កុមារភាព (Chemins D'enfances) បានរៀបចំបង្កើតឡើងនូវកម្មវិធីល្បែងសេរីក្នុងគោលបំណងជួយកុមារឱ្យមានការអភិវឌ្ឍលើផ្នែកទាំងបួនរួមមានរាងកាយ បញ្ញា ភាសា និងសញ្ចេតនាទាក់ទងនឹងសង្គម។ លើសពីនេះទៅទៀត ល្បែងសេរីធ្វើឱ្យកុមារមានបំណិនក្នុងការលេងល្បែងដោយក្ដីសប្បាយរីករាយ តាមការចូលចិត្តប្រកបដោយទំនុកចិត្ត សុវត្ថិភាព និងភាពម្ចាស់ការ។

ខែតុលាឆ្នាំ ២០១៣គម្រោងបានចាប់ផ្ដើមអនុវត្តក្នុងសាលាមត្តេយ្យសហគមន៍ចំនួន៩នៃតំបន់គោលដៅគឺតំបន់ជាយក្រុងភ្នំពេញ ខេត្តកណ្ដាល និងខេត្តតាកែវ ដោយផ្ដល់ឱកាសដល់កុមារចំនួន៧៨០នាក់ ស្រី៤១៨នាក់ បានចូលរួមសកម្មភាពល្បែងសេរី។ ត្រីមាសទី៣នៃឆ្នាំ២០១៤ បានពង្រីកសកម្មភាពនេះទៅសាលាមត្តេយ្យសហគមន៍ថ្មីចំនួន២សាលាទៀត មានកុមារចូលរួម១២៦នាក់ ស្រី៧៣នាក់។ សរុបទាំងអស់ក្នុងឆ្នាំ២០១៤ មាន១១សាលាបានទទួលកម្មវិធីល្បែងសេរីដែលមានកុមារចូលរួមសរុប៩០៦នាក់ ស្រី៤៩១នាក់។ លទ្ធផលនៃការអនុវត្តន៍គម្រោងល្បែងសេរីក្នុងឆ្នាំ២០១៤នេះមានដូចខាងក្រោម៖

- តាមរយៈការតាមដានសង្កេតជាទូទៅនិងជាបុគ្គលទៅលើសកម្មភាពលេងរបស់កុមារចំពោះល្បែងទាំងបួនប្រភេទ (ល្បែងហាត់ត្រាប់តាម/និមិត្តរូប ផ្គុំ/សាងសង់ និងល្បែងមានក្បួន) បង្ហាញឱ្យឃើញថា កុមារទាំង៩០៦នាក់ (ស្រី៤៩១នាក់) ទទួលបាននូវភាពសប្បាយរីករាយដោយបង្កប់នូវការអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយ និងមានចំណង់មកសាលារៀនទៀតផង (អត្រាកំណើនការចុះឈ្មោះចូលរៀនរបស់កុមារសាលាមត្តេយ្យ)។





- គ្រូមត្តេយ្យស្ម័គ្រចិត្តចំនួន២៧នាក់ (ស្រី២៧នាក់) នៃសាលាទាំង១១បានទទួលការបណ្តុះបណ្តាលបន្តនៅនឹងកន្លែង(ក្រោយពេលបញ្ចប់ម៉ោងលេងរបស់កុមារ) អំពីខ្លឹមសារសំខាន់ៗរបស់ល្បែងសេរីដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនលើការរៀបចំដំណើរការល្បែងសេរីឲ្យមានគុណភាពប្រសិទ្ធភាព និងទំនុកចិត្ត។
- ក្រោយពីបានធ្វើការវាយតម្លៃចំណេះដឹងរបស់គ្រូទាក់ទងនឹងល្បែងសេរីដោយប្រើប្រាស់ឧបករណ៍វាយតម្លៃទៅលើសមត្ថភាពគ្រូចំពោះសាលាមត្តេយ្យសហគមន៍ទាំង៩ដែលបានអនុវត្តសកម្មភាពនេះតាំងពី ខែតុលាឆ្នាំ២០១៣មក យើងក៏បានរៀបចំសាលាមត្តេយ្យទាំង៩នេះឲ្យស្វ័យភាពល្បែងសេរីដោយផ្តល់ជូននូវសម្ភារល្បែងទាំង៤ប្រភេទសម្រាប់សាលានីមួយៗអនុវត្ត និងដឹកនាំសកម្មភាពនេះដោយភាពម្ចាស់ការខ្លួនឯង(ឯកសារតម្កល់ទុកលិខិតប្រគល់សម្ភារល្បែងសេរី)។
- នៅពេលវិស្សមកាលធំ(ខែសីហា កញ្ញា តុលា) យើងបានអនុវត្តសកម្មភាពល្បែងសេរីក្នុងភូមិតាមរយៈការប្រជុំក្រុមឪពុកម្តាយ ចំនួន១១ដែលជាភូមិគោលដៅចំណុះឲ្យសាលាមត្តេយ្យសហគមន៍ ដែលមានឪពុក ម្តាយចូលរួមប្រជុំចំនួន២៥៥នាក់ស្រី១៩២នាក់ និងកុមារចូលលេងល្បែងសេរី ចំនួន៦១០នាក់ ស្រី២៩៧ នាក់ ។ យើងសង្កេតឃើញថាការនាំយកល្បែងសេរីទៅចូលរួមក្នុងកម្មវិធីប្រជុំក្រុមឪពុកម្តាយ គឺទទួលបាន លទ្ធផលជាវិជ្ជមាន ព្រោះឪពុកម្តាយមានភាពងាយស្រួលក្នុងការពិភាក្សាគ្នាដោយ មិនមានការរំខានពី កូនចៅតូចៗរបស់គាត់។ ឯកុមារបានលេងសប្បាយប្រកបដោយភាពឈ្លាសវៃ ច្នៃប្រឌិត សហការ ចែករំលែកគ្នាលេងនិងមានភាពស្និទ្ធស្នាលថែមទៀត។ម្យ៉ាងទៀតឪពុកម្តាយក៏កាន់តែយល់ច្បាស់អំពីសារសំខាន់នៃល្បែងលេងនៅក្នុងការអភិវឌ្ឍរបស់កុមារហើយក៏បានទទួលបទពិសោធន៍អំពីការផលិតល្បែងលេងនានាដោយប្រើប្រាស់ ធនធានសម្ភារដែលអាចរកបានក្នុងមូលដ្ឋានទុកឱ្យកូនលេងនៅផ្ទះព្រមទាំងបានចូលរួមជួយផលិតល្បែងលេងបន្ថែមទៀតនៅតាមសាលាមត្តេយ្យដែលបានស្វ័យភាពល្បែងសេរីសម្រាប់ទុកឲ្យកុមារលេងនៅសាលាទៀតផង។





➢ ដើម្បីផ្សព្វផ្សាយកម្មវិធីល្បែងសេរីឲ្យកាន់តែទូលំទូលាយថែមទៀតយើងក៏បានរៀបចំវគ្គបណ្តុះបណ្តាលអំពីល្បែងសេរីចែកជូនដល់គ្រូខ្មែរមកពីអង្គការនានាចំនួន១០អង្គការ និងបុគ្គលិកសមាគមគ្រួសារយើងចំនួន៤នាក់ទៀត សរុបសិក្ខាកាមទាំងអស់មានចំនួន១៤នាក់ ស្រី៧នាក់ ទៅលើខ្លឹមសារសំខាន់ៗនៃល្បែងសេរីព្រមទាំងមានធ្វើកម្មសិក្សាប្រតិបត្តិផ្ទាល់នៅតាមសាលាមត្តេយ្យសហគមន៍ដើម្បីបានអនុវត្តជាក់ស្តែង ក្នុងការពង្រឹងសមត្ថភាពសម្រាប់យកទៅផ្ទេរជូនដល់បុគ្គលិកក្រុមការងារតាមបណ្តាអង្គការរៀងៗខ្លួនឈានទៅពង្រីកសកម្មភាពនេះឲ្យទទួលបានជោគជ័យ និងប្រសិទ្ធភាពជាបន្តទៀត។

**បញ្ហាប្រឈម**

- មានការផ្លាស់ប្តូរសមាសភាពគ្រូថ្មីមិនទាន់បានឆ្លងកាត់សកម្មភាពល្បែងសេរី។
- គ្រូមត្តេយ្យមួយចំនួនមានកម្រិតវប្បធម៌ទាបនិងមានវ័យចាស់ពិបាកក្នុងការបណ្តុះបណ្តាលបន្ត(ភ្លេចច្រើន ពិបាកកត់ត្រា)។

**ដំណោះស្រាយ**

- ប្រជុំពិភាក្សា បំប៉នបន្ថែមក្រោយពេលកុមារលេងចប់ ដើម្បីពង្រឹងសមត្ថភាពគាត់ឱ្យអាចអនុវត្តសកម្មភាពដោយខ្លួនឯងបាន
- សង្ខេបខ្លឹមសារឱ្យបានខ្លីបំផុត ចំណាយពេលយូរជាងគ្រូដ៏ទៃបន្តិច ក្នុងការពន្យល់ និងហៅឱ្យកត់ត្រាទុកមើលឡើងវិញពេលភ្លេច។ នាំគាត់ឱ្យអនុវត្តផ្ទាល់ជាមួយយើង(រៀបចំទីតាំង ដាក់ល្បែងតាមដានសង្កេត រៀបចំទុកដាក់វិញ)ឱ្យបានញឹកញាប់។

**ចំណុចខ្លាំង**

- ភាគច្រើននៃសម្ភារល្បែងសេរីឆ្លើយតបនឹងតម្រូវការ និងចំណង់ចំណូលចិត្តរបស់កុមារ។
- ល្បែងសេរីបានបង្កើនអត្រាចុះឈ្មោះចូលរៀនរបស់កុមារនៅតាមសាលាមត្តេយ្យ។

**មេរៀនបទពិសោធន៍**

- ការបណ្តុះបណ្តាលបន្ត(នៅនឹងកន្លែង) អំពីល្បែងសេរីដល់គ្រូមត្តេយ្យគឺអាចពង្រឹងសមត្ថភាពគ្រូឱ្យអនុវត្តការងារនេះបានល្អនាពេលអនាគត។
- មានល្បែងសេរីនៅសាលាធ្វើឱ្យកុមារមានចំណង់មកសាលារៀន។

## -ការបង្កើតល្បែងគរុកោសល្យ

សមាគមគ្រួសារយើង យល់ច្បាស់ថា **លេង** គឺជាតម្រូវការចម្បង និងចាំបាច់ចំពោះការអភិវឌ្ឍន៍របស់កុមារ។ ដូចនេះហើយ ទើបក្រុមការងារគាំពារ និងអភិវឌ្ឍន៍កុមារតូច របស់សមាគមគ្រួសារយើង បានផលិតល្បែងជាច្រើន សម្រាប់បម្រើដល់ការងារគាំពារ និងអភិវឌ្ឍន៍កុមារតូចនេះ។

# ល្បែងបង្កើតថ្មី



ល្បែងៈ ភូមិសុវត្ថិភាព(ធ្វើតុក្កតាឈើ)



ល្បែងឧបករណ៍ភ្លេងប្រពៃណី



ល្បែងដកផ្សិត



ល្បែងគៀងគោចូលក្រោល



ខំប្រឹងឡើងដើម្បីឈ្នះ



ល្បែងដៃទិព្វភ្នែកទិព្វ

បច្ចុប្បន្ន សមាគមគ្រួសារយើង ផលិតល្បែងបានច្រើនជាង **១០០ ប្រភេទផ្សេងៗគ្នា** ជាគម្រូសម្រាប់អង្គការដទៃទៀត ដែលធ្វើការងារជាមួយកុមារតូច។ គម្រូនៃល្បែងទាំងនោះ មាននៅការិយាល័យសមាគមគ្រួសារយើង៖

អាស័យដ្ឋាន៖ ផ្ទះលេខ ១៨អា ផ្លូវលេខ ៦០៤ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខ៖ ០២៣ ៨៨៤ ៨០៤/៥ ឬ អ៊ីម៉ែល: krousaryoeung@online.com.kh

## -ការចែករំលែកបទពិសោធន៍ទាក់ទងនឹងការងារអប់រំកុមារតូច

**<u>បណ្តាញក្រុមការងារគាំពារ និងអភិវឌ្ឍន៍កុមារតូច (NECCD)</u>**

ក្នុងឆ្នាំ២០១៤នេះ សមាគមគ្រួសារយើង នៅតែត្រូវបានជ្រើសតាំងឱ្យធ្វើជាប្រធានបណ្តាញក្រុមការងារគាំពារ និងអភិវឌ្ឍន៍កុមារតូច ដែលមានសមាជិកចំនួន៣២អង្គការ ។ បណ្តាញនេះបានបង្កើតឡើងនៅឆ្នាំ១៩៩៦ ដោយអង្គការកុមារកម្ពុជា(អង្គការ កុមារ និង អភិវឌ្ឍន៍) ផ្នែកអប់រំកុមារតូច បច្ចុប្បន្នជាអង្គការក្នុងស្រុកឈ្មោះសមាគមគ្រួសារយើង។

បណ្តាញនេះមានគោលបំណងដូចខាងក្រោម៖

- ពង្រីកសកម្មភាពអប់រំកុមារតូច ឆ្លើយតបទៅនឹងតម្រូវការរបស់កុមារនៅក្នុងប្រទេសកម្ពុជា
- ពង្រឹងសកម្មភាពនានាទាក់ទងនឹងការអប់រំ ថែទាំគាំពារកុមារតូចនៅកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍកុមារ
- អនុវត្តតាមគោលនយោបាយជាតិ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលទាក់ទងនឹងការអប់រំថែទាំគាំពារកុមារតូច
- ចែករំលែកបទពិសោធន៍ស្តីពីការងារអប់រំថែទាំកុមារតូចដល់សង្គមស៊ីវិល និងរដ្ឋាភិបាល
- ផ្សព្វផ្សាយពីការរកឃើញនានាដែលទាក់ទងនឹងការគាំពារ និងអភិវឌ្ឍកុមារតូច ក្នុងរង្វង់ឪពុកម្តាយ និងអ្នកដែលរស់នៅជាមួយកុមារ
- ស្រាវជ្រាវនិងផលិតឯកសារនានា (ឯកសារគរុកោសល្យសៀវភៅរឿង ចម្រៀង ល្បែងកំសាន្ត) ដើម្បីឆ្លើយតបនឹងតម្រូវការរបស់កុមារ

សមាគមគ្រួសារយើងបានដឹកនាំ និងរៀបចំការប្រជុំចំនួន៤ដង និងការចុះធ្វើទស្សនកិច្ចសិក្សាចំនួន១ដង (នៅសាលាមត្តេយ្យអនុវត្តន៍គោករកា សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ) ដោយមានការចូលរួមពីអង្គការសមាជិកចំនួន១៨នាយកដ្ឋានអប់រំកុមារតូច និងនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ។ លទ្ធផលសម្រេចបានរួមមាន៖

- បណ្តាញក្រុមការងារគាំពារ និងអភិវឌ្ឍន៍កុមារតូច បានដំណើរការ ប្រៀបដូចជាក្រុមពិគ្រោះយោបល់មួយសម្រាប់ផ្តល់មតិយោបល់ ដល់អង្គការសមាជិក ក្នុងការងារបង្កើតឯកសារថ្មីៗ ឆ្លើយតបទៅនឹងតម្រូវការ នៃការអភិវឌ្ឍន៍កុមារតូច (ឧទាហរណ៍: ការបង្កើតវីដេអូសម្រាប់បណ្តុះបណ្តាលគ្រូចំនួន៤ គឺគណិតវិទ្យានៅមត្តេយ្យសិក្សា (វិស័យបរិមាណ-ចំនួន និងវិស័យរង្វាស់) និង បុរេសំណេរ(បំណិនស្តាប់ និង ស្គាល់អក្សរមួយ

ពេល) ។ ព្រមទាំងការធ្វើបច្ចុប្បន្នភាពសៀវភៅគណិតវិទ្យានៅមត្តេយ្យសិក្សា និង គំនូសនិងការត្រៀមកុមារឱ្យហាត់សរសេរផ្នែកមត្តេយ្យសិក្សាក៏ត្រូវបានយកមកពិភាក្សាពីការជ្រើសរើសសមាសភាពគណៈកម្មការ។ សៀវភៅទាំងពីរនេះបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡាព្រមទាំងអនុញ្ញាតឱ្យប្រើប្រាស់ពីពេលនេះតទៅ។

- សមាជិក **NECCD** ចំនួន៨នាក់(គ្រួសារយើង ១នាក់ អង្គការក្លែនអន្តរជាតិ ២នាក់ សមាគមបណ្តុះកុមារ ២នាក់ អង្គការសង្គ្រោះកុមារ៣នាក់ បានចូលរួម នៅក្នុងសន្និបាតប្រចាំឆ្នាំរបស់**ARNEC** នៅប្រទេសហ្វីលីពីន។ គណៈកម្មការសិទ្ធបានផ្តល់ឱកាសឱ្យលោកស្រី គីសំភីតំណាងឱ្យសមាគមគ្រួសាយើង និង **NECCD**បានធ្វើបទបង្ហាញស្តីពីសកម្មភាពនិងមេរៀន បទពិសោធន៍របស់គម្រោង មជ្ឈមណ្ឌលធនធានអប់រំ កុមារតូច**(ECRC)**
- សមាជិក **NECCD** ចំនួន ១១នាក់ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីល្បែងសេរី។ សមាជិកចូលរួមមានអង្គការមនុស្សលោកថ្មី ១នាក់ សមាគមគ្រួសារយើង៥នាក់ អង្គការសមត្ថភាពខ្ញុំ ១នាក់ សកលវិទ្យាល័យបញ្ញាសាស្ត្រ ១នាក់ អង្គការ Aide et Action ១នាក់ អង្គការសុវណ្ណកុមារ ១នាក់ និង អង្គការ ADRA ១នាក់ សមាជិកដែលបានចូលរួមវគ្គបានប្តេជ្ញាថា នឹងចែកចំណេះដឹងពីល្បែងសេរីទៅក្រុមការងាររបស់ខ្លួនតាមរយៈការបណ្តុះបណ្តាល។
- សមាជិកទាំងអស់ បានចែករំលែកគ្នាទៅវិញទៅមក នូវបទពិសោធន៍ល្អៗរបស់ខ្លួនក្នុងការអនុវត្តន៍គម្រោងនានាពាក់ព័ន្ធនឹងការងារគាំពារ និងអភិវឌ្ឍន៍កុមារតូច។ តាមរយៈការចែករំលែកនេះ សមាជិកបណ្តាញបានយល់ដឹងកាន់តែច្បាស់ពីយុទ្ធសាស្ត្រ ក្នុងការអនុវត្តន៍គម្រោងគាំពារ និងអភិវឌ្ឍន៍កុមារតូច ប្រកបដោយប្រសិទ្ធភាព (ការងារអប់រំឪពុកម្តាយ យុទ្ធសាស្ត្រក្នុងការងារគ្រប់គ្រងដំណើរការសាលាមត្តេយ្យសហគមន៍ និងកម្មវិធីសម្រាប់ការអប់រំកុមារតូច) សម្រាប់ប្រើប្រាស់ក្នុងការពង្រឹងសកម្មភាពគាំពារ និងអភិវឌ្ឍន៍កុមារតូច។
- បណ្តាញនេះ បានដើរតួនាទីជាវេទិកាសម្រាប់សមាជិកចែករំលែកនូវឯកសារថ្មី គំនិតផ្តួចផ្តើមថ្មីៗ និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងវិស័យគាំពារ និងអភិវឌ្ឍន៍កុមារតូច រួមមាន ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍន៍កុមារតូចឆ្នាំ ២០១៤-២០១៨ គោលការណ៍ណែនាំ ស្តីពីការបង្កើតសៀវភៅសម្រាប់កុមារតូច ការបណ្តុះបណ្តាលស្តីពីល្បែងសេរី ការភ្ញោចឱ្យកុមារតូចមានការអភិវឌ្ឍ និងព័ត៌មានស្តីពី សិក្ខាសាលាជាតិ និងអន្តរជាតិ ព្រមទាំងឯកសារថ្មីជាច្រើន ។





# គេហទំព័ររបស់មជ្ឈមណ្ឌលធនធានកុមារតូច

ក្នុងឆ្នាំ២០១៤នេះ យើងបានបញ្ចូលនិងបង្ហោះព័ត៌មានជាច្រើនទៅក្នុងគេហទំព័រនេះដូចជា ការចូលរួមសិក្ខាសាលាអន្តរជាតិរវាងប្រទេសកម្ពុជា និង ប្រទេសប៊ូគីណាហ្វាសូ ការផលិតសៀវភៅសម្រាប់កុមារតូច សកម្មភាពផ្សេងៗទាក់ទងនឹងសហគមន៍។ ផ្នែកឧបករណ៍ បានបញ្ចូលឧបករណ៍ទាក់ទងនឹងការងារអប់រំកុមារតូច ការគាំទ្រការងារអប់រំរបស់ឪពុកម្តាយចំពោះកូនៗ ការពង្រឹងភាពស្វាហាប់ក្នុងសហគមន៍។

ចំណែកផ្នែកផ្សេងៗទៀតដូចជា បណ្តាញការងារគាំពារនិងអភិវឌ្ឍកុមារតូច ព្រឹត្តបត្រព័ត៌មានមត្តេយ្យសិក្សាក៏ត្រូវបានបញ្ចូលជាបន្តបន្ទាប់។

ចំពោះកំណើនអ្នកប្រើប្រាស់គេហទំព័រនេះមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។







## បញ្ហាប្រឈម

- ការប្រជុំប្រចាំពីរខែម្តងមិនបានសម្រេចតាមផែនការ (៦ដងក្នុង១ឆ្នាំ) ដោយសារអង្គការ-សមាគមនីមួយៗមានការមមាញឹក។
- ការចូលរួមប្រជុំរបស់សមាជិកដែលតំណាងមកពីអង្គការ ឬ ស្ថាប័ន មិនទៀងទាត់ និងមានការផ្លាស់ប្តូរញឹកញាប់។ សមាជិកគណៈកម្មការប្រតិបត្តិពុំសូវមានពេលចូលរួម ។ អង្គការ សមាគម ពុំបានគ្រោងថវិកាចូលរួមវិភាគទាន ។

## មេរៀនបទពិសោធន៍

- សមាជិកផ្លាស់ប្តូរបទពិសោធន៍រៀងរាល់ពីរខែម្តង ដែលជាកត្តាជួយពង្រីក និងពង្រឹងសកម្មភាពរបស់អង្គការនីមួយៗផង និងមានគំនិតផ្តួចផ្តើមថ្មីៗទៀតស្តីពីការងារគាំពារ និង អភិវឌ្ឍន៍កុមារតូច។
- សមាជិកមានសិទ្ធិទទួលព័ត៌មានពីរដ្ឋាភិបាល សង្គមស៊ីវិល និងរបកគំហើញថ្មីៗ ពីអ្នកជំនាញផ្នែកអប់រំកុមារតូច។
- ដឹងពីផែនការ-ការលំបាក បញ្ហាប្រឈម ហើយត្រៀមដោះស្រាយ ។

## ៤.២. ក្លឹបកុមារៈ ការរៀនសូត្រ និងការលើកកម្ពស់ការគោរពសិទ្ធិកុមារ

កុមារ គឺជាស្នូលនៃការអភិវឌ្ឍដែលមិនអាចខ្វះបានទាំងក្នុងគ្រួសារ ទាំងក្នុងសហគមន៍ និងទាំងក្នុងប្រទេសជាតិ។ ក្នុងន័យនេះ សមាគមគ្រួសារយើងបានខិតខំយកចិត្តទុកដាក់ខ្ពស់ចំពោះការគោរពសិទ្ធិកុមារ និងការរៀនសូត្ររបស់កុមារ តាមរយៈការបង្កើតសកម្មភាពក្លឹបកុមារនៅក្នុងសហគមន៍ ដើម្បីបង្កលក្ខណៈជួយអភិវឌ្ឍន៍ដល់កុមារឱ្យបានគ្រប់ជ្រុងជ្រោយក្នុងពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគត។

គោលបំណងនៃការបង្កើតក្លឹបកុមារនេះ គឺដើម្បីជំរុញឱ្យកុមារក្នុងសហគមន៍ ជាពិសេសកុមារក្នុងគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះបំផុត[2] យល់ដឹង និងចេះអនុវត្តសិទ្ធិទាំងបួនរបស់ពួកគេ[3]ប្រកបដោយទំនុកចិត្តខ្ពស់ ហើយទទួលបានការអភិវឌ្ឍផ្នែកចំណេះដឹង និងជំនាញ(បំណិនជីវិត)តាមរយៈការចូលរួមកិច្ចប្រជុំប្រចាំខែ និងវគ្គបណ្តុះបណ្តាលផ្សេងៗ។ សកម្មភាពរួមចំណែកជួយជំរុញឱ្យកុមារ(ជាពិសេសកុមារី និងកុមារងាយរងគ្រោះ[4]) រៀនចប់កម្រិតថ្នាក់មូលដ្ឋាន កាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សា។ បច្ចុប្បន្ន សមាគមគ្រួសារយើងបានបង្កើត ក្លឹបកុមារចំនួន៦៧ក្លឹប (ខេត្តសៀមរាបមាន២៥ក្លឹប ខេត្តកំពង់ចាមមាន ១៩ក្លឹប និងនៅជាយក្រុងភ្នំពេញមាន២៣) និងបង្កើតគណៈកម្មការគាំទ្រក្លឹបកុមារចំនួន១៦ (គណៈកម្មការចំនួន៨នៅខេត្តសៀមរាបនិង៨ទៀតនៅខេត្តកំពង់ចាម) ដែលមានសមាជិកសរុប៣,៦៩៦ នាក់ (ស្រី២,០៤៥ នាក់) ដើម្បីគាំទ្រ និងតាមដាន ដំណើរការរបស់ក្លឹបកុមារទាំងអស់នោះ។ ក្នុងឆ្នាំ២០១៤នេះ យើងបានសម្រេចនូវលទ្ធផលដូចខាងក្រោមៈ

- សមាគមគ្រួសារយើងបន្តការពង្រឹងកិច្ចសហការល្អជាមួយការិយាល័យអប់រំស្រុក និងមន្ទីរអប់រំយុវជននិងកីឡាខេត្ត ដើម្បីបំប៉នសមត្ថភាពបន្ថែមដល់លោកគ្រូ អ្នកគ្រូ នាយកសាលា គណៈកម្មការទ្រទ្រង់សាលា រួមទាំងគ្រូមត្តេយ្យសហគមន៍ក្នុងតំបន់គោលដៅ ក្រោមប្រធានបទ អភិបាលកិច្ចល្អរបស់សាលារៀន ក្នុងគោលបំណងបង្កើនគុណភាពអប់រំ ជាពិសេសសាលានៅក្នុងតំបន់ជនបទដាច់ស្រយាល។
- បច្ចុប្បន្ន ៨៨.៩៣% នៃប្រធាន និងអនុប្រធានក្លឹបកុមារ ២៧៩នាក់(ស្រី១៣២នាក់) មានសមត្ថភាពគ្រប់គ្រាន់អាចដឹកនាំកិច្ចប្រជុំប្រចាំខែរបស់ក្លឹបកុមារបានទៀងទាត់។ តាមរយៈការចូលរួមក្នុងកិច្ចប្រជុំក្លឹបកុមារប្រចាំខែ ការអង្កេត និងវាយតម្លៃ ឃើញថា ៩៥% នៃ សមាជិកក្លឹបទាំងអស់២,៧៩៩នាក់ (ស្រី ១,៦៣៦នាក់)ស្គាល់ពីសិទ្ធិទាំង៤ របស់ពួកគេ មានភាពក្លាហានក្នុងការចូលរួមកិច្ចប្រជុំប្រចាំភូមិ និងហ៊ានលើកឡើងពីកង្វល់ដែលខ្លួន និងកុមារដទៃបានជួបប្រទះមានបំណិនជីវិតផ្សេង យល់ដឹងពីតម្លៃនៃការសិក្សា និងមានវប្បធម៌ក្នុងការចែករំលែក (សិស្សពូកែបង្រៀនសិស្សខ្សោយក្នុងកិច្ចប្រជុំក្លឹបកុមារប្រចាំខែ) ព្រមទាំងទទួលបានចំណេះដឹងស្តីពីការអនុវត្តន៍ ទម្លាប់អនាម័យល្អ និងការបង្ការជំងឺផ្សេងៗ ។
- ៨៨%នៃសមាជិកក្លឹបកុមារទាំងអស់ បានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពក្លឹបកុមារ និងទៅសាលារៀនទៀងទាត់ ហើយទទួលបានលទ្ធផលសិក្សាល្អ (ជាប់មធ្យមភាគទាំងអស់)។ លើសពីនេះទៀតកុមារចំនួន ២៣.១៨% (៦៤៩ នាក់/ស្រី ៣៧៩នាក់) បានជាប់ចំណាត់ថ្នាក់ពីលេខ ១ ដល់លេខ ១០។

---

[2]រួមមាន ស្ត្រីមេម៉ាយជាមេគ្រួសារ គ្រួសារមានអំពើហិង្សា គ្រួសារដែលមានជនពិការ និងចាស់ជរាក្នុងបន្ទុក គ្រួសារដែលមានសមាជិកផ្ទុកមេរោគ។

[3] សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍន៍ សិទ្ធិក្នុងការចូលរួម និងសិទ្ធិទទួលបានការការពារ។

[4]កុមារជាមេគ្រួសារ កុមារពិការ កុមារផ្ទុកមេរោគអេដស៍។

បន្ថែមពីលើសកម្មភាពនៃកិច្ចប្រជុំប្រចាំខែរបស់ក្លឹបកុមារ សមាគមគ្រួសារយើងបានរៀបចំសកម្មភាពគាំទ្រ អាហារូបករណ៍ (ផ្តល់សម្ភារសិក្សា) ដល់សមាជិកក្លឹបជាសិស្សក្រីក្រ។ យើងក៏បានរៀបចំវេទិកាស្តីពីសិទ្ធិកុមារ (ដោយមានការចូលរួមពីកុមារ និងមាតាបិតា គ្រូបង្រៀន និងអាជ្ញាធរពាក់ព័ន្ធ) ដើម្បីផ្តល់ឱកាសដល់កុមារក្នុងការបង្ហាញពីបញ្ហាដែលពួកគេបានជួបប្រទះនិងរកដំណោះស្រាយ ក្នុងគោលបំណងលើកកម្ពស់ការគោរពសិទ្ធិកុមារនៅក្នុងសហគមន៍។ តាមរយៈការអនុវត្តន៍សកម្មភាពខាងលើនេះ សមាគមគ្រួសារយើងសម្រេចបាននូវលទ្ធផលសំខាន់ៗ ដូចខាងក្រោមៈ

- កុមារចំនួន១,១២៦នាក់(ស្រី៥១៨នាក់) (សៀមរាបៈ ៣២៣នាក់/ស្រី១៨៦នាក់ កំពង់ចាម ២២៣នាក់/ស្រី១៣៥នាក់និងជាយរាជធានីភ្នំពេញ ៥៨០នាក់/ស្រី១៩៧នាក់) បានបន្តការសិក្សាយ៉ាងខ្ជាប់ខ្ជួន យើងក៏បានផ្តល់ការគាំទ្រផ្នែកសម្ភារសិក្សា (កាតាបសៀវភៅ ប៊ិចខៀវ-ក្រហម ខ្មៅដៃ ជ័រលុប បន្ទាត់ កាប៉ា សម្លៀកបំពាក់ឯកសណ្ឋាន ស្បែកជើង និងកង់។ល។)
- អាជ្ញាធរមូលដ្ឋាន និងមន្ត្រីរដ្ឋាភិបាលចំនួន៥២៦នាក់ (ស្រី១៧៦នាក់) និងមាតាបិតានៃគ្រួសារគោលដៅ ចំនួន ១,៩០៦ គ្រួសារនិងគ្រួសារមិនមែនដៃគូចំនួន២,២៤៦គ្រួសារបានយល់ដឹងពីសិទ្ធិកុមារ (ខេត្តកំពង់ចាម និង សៀមរាប) តាមរយៈវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ សិទ្ធិជនពិការ យេនឌ័រ បម្រែបម្រួលអាកាសធាតុ ការប្រឹក្សាយោបល់ និងវេទិកាស្តីពីសិទ្ធិកុមារ ហើយអ្នកមានកាតព្វកិច្ច ទាំងអស់នោះ បានតាំងចិត្តថានឹងដោះស្រាយបញ្ហាដែលកុមារបានជួបប្រទះ ជាពិសេសពាក់ព័ន្ធទៅនឹងការអប់រំ កុមារ។
- គណកម្មការគាំទ្រក្លឹបកុមារ សហការជាមួយគណកម្មការកិច្ចការនារី និងកុមារថ្នាក់ឃុំ-ស្រុក បានខិតខំប្រឹងប្រែង និងជួយជ្រោមជ្រែងក្នុងដំណើរការក្លិបកុមារនៅក្នុងសហគមន៍ឱ្យមាន ដំណើរការល្អទាំងការប្រជុំប្រចាំខែ និងការជួយអន្តរាគមន៍ដល់កុមារដែលជួបឧបសគ្គក្នុងការរៀនសូត្រ ឬមានការរំលោភបំពានដល់ពួកគាត់។





# ស្ថិតិកុមារក្នុងក្លឹបសិក្សា

| ខេត្ត គោលដៅ | ចំនួន ក្លឹប | មេដឹកនាំក្លឹប | សមាជិក | សមាជិកដែល ទទួលបានការគាំទ្រ សម្ភារសិក្សា | ស្ថិតក្នុងក្របខ័ណ្ឌនៃគម្រោង |
|---|---|---|---|---|---|
| សៀមរាប | ២៥ | ៧៥ (ស្រី៤១) | ១,៥៣៩(ស្រី ៩៣៨) | ៣២៣ (ស្រី ១៨៦) | *ពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់គ្រួសារ (គាំទ្រដោយអង្គការភ្លែន អូស្រ្តាលី)* |
| កំពង់ចាម | ១៩ | ៦៣ (ស្រី៤៩) | ១,២៦០(ស្រី ៦៩៨) | ២២៣ (ស្រី ១៣៥) | |
| ជាយក្រុង ភ្នំពេញ | ២៣ | ១១១(ស្រី ៥៦) | ៤១១ (ស្រី១៨៤) | ៣៤៥ (ស្រី១៧១) | *អប្បារាអ៊ីតាលី* |
| **សរុប** | **៦៧** | **២៤៩ (ស្រី ១៤៦)** | **៣,២១០ (ស្រី១,៨២០)** | **៨៩១ (ស្រី ៤៩២)** | |

## បញ្ហាប្រឈម

- ការផ្លាស់ប្តូរប្រធានក្លឹបញឹកញាប់ធ្វើឱ្យការដឹកនាំក្លឹបចុះខ្សោយ។
- កុមារចំណាកស្រុកជាមួយឪពុកម្តាយ/អាណាព្យាបាលធ្វើឱ្យពួកគាត់បាត់បង់ឱកាសរៀនសូត្រ និង បោះបង់ការសិក្សាចោលទាំងមិនទាន់ចប់កម្រិតថ្នាក់មូលដ្ឋាន។
- កុមាររៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង(អាយុ១៦ទៅ១៨ឆ្នាំ)។
- កុមារតែងចំណាយពេលក្រៅពីការសិក្សានៅក្នុងថ្នាក់មកជួយធ្វើកិច្ចការរកប្រាក់ចំណូលផ្សេងៗ។

## ដំណោះស្រាយ

- ចុះពង្រឹងក្លឹបដែលដឹកនាំសកម្មភាពនៅខ្សោយបានច្រើនដងក្នុង១ខែ។ និងយកប្រធានក្លឹបដែលរឹងមាំទៅជួយចែករំលែកបទពិសោធដល់ក្លឹបមិនទាន់ម្ចាស់ការ។
- ពង្រឹងឆន្ទៈកុមារឱ្យយល់ពីតម្លៃនៃការសិក្សា និងផលវិបាកដែល អាចកើតមានឡើងពេលធ្វើចំណាកស្រុក ហើយសហការជាមួយ អាជ្ញាធរមូលដ្ឋាន លោក/អ្នកគ្រូជួយអប់រំណែនាំដល់ប្រជាជន និងកុមារកុំឱ្យធ្វើចំណាកស្រុកដោយប្រថុយប្រថាន។
- ព្យាយាមជួបកុមារនៅតាមផ្ទះ និងបង្ហាញពីតម្លៃនៃការចូលរួមសកម្មភាពក្លឹបកុមារ។

## ៤.៣. ការគាំទ្រ និងការពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវ របស់គ្រួសារ

ការប្រឹក្សាយោបល់ជាមួយគ្រួសារក្រីក្រ






ការអភិវឌ្ឍន៍ជីវភាពគ្រួសារ





ការលើកស្ទួយសុខភាពគ្រួសារ





ការបណ្តុះបណ្តាលវិជ្ជាជីវៈ








## ៤.៣.១. ការប្រឹក្សាយោបល់ជាមួយគ្រួសារក្រីក្រ



*លោក **ដាំ យន់** បុគ្គលិកប្រឹក្សាយោបល់កំពុងផ្តល់ការប្រឹក្សាយោបល់ជំហានទី៥ដល់គ្រួសារគោលដៅ ក្នុងភូមិត្រពាំងស្វាយ ស្រុកអង្គរធំ ខេត្តសៀមរាប។*

សមាគមគ្រួសារយើង បានចាប់ផ្តើមអនុវត្តការងារប្រឹក្សាយោបល់តាំងពីឆ្នាំ២០០៤ រហូតមក ដល់ពេលបច្ចុប្បន្នហើយត្រូវបានអង្គការដៃគូនានាទទួលស្គាល់ថា មានភាពខ្លាំងក្នុងការធ្វើការប្រឹក្សាយោបល់ជាគ្រួសារក្រីក្របំផុត។ ការងារប្រឹក្សាយោបល់ គឺជាដំណើរការនៃការផ្តល់ការប្រឹក្សា(មាន៥ជំហាន)ដល់គ្រួសារក្រីក្រ និងគ្រួសារងាររងគ្រោះ[5] ដើម្បីឱ្យពួកគាត់មានជំនឿទុកចិត្តលើខ្លួនឯង និងមានភាពម្ចាស់ការ ក្នុងការលើកកម្ពស់គុណភាពជីវភាពរស់នៅរបស់ពួកគាត់ តាមរយៈការស្វែងយល់ពីបញ្ហា[6] ស្វែងរកដំណោះស្រាយ និងប្រើប្រាស់ភាពខ្លាំងដែលគាត់មានសម្រាប់ធ្វើផែនការអភិវឌ្ឍន៍គ្រួសារ។




គោលដៅចម្បងនៃការអនុវត្តន៍ការងារប្រឹក្សាយោបល់នេះ គឺដើម្បីពង្រឹងសមត្ថភាព និងភាពជឿជាក់របស់មេគ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះក្នុងការពង្រឹងទំនុកចិត្តដើម្បីឈានដល់ការលើកស្ទួយកម្រិតជីវភាពគ្រួសាររបស់ពួកគេឱ្យប្រសើរឡើង។ គ្រួសារក្រីក្រអាចប្រើប្រាស់សេវាសង្គមចាំបាច់ផ្សេងៗ និងការ

[5] រួមមាន ស្ត្រីមេម៉ាយជាមេគ្រួសារ គ្រួសារមានអំពើហិង្សា គ្រួសារដែលមានជនពិការ និងចាស់ជរាក្នុងបន្ទុក គ្រួសារដែលមានសមាជិកផ្ទុកមេរោគ កុមារកំព្រា ជាមេគ្រួសារ និងគ្រួសាររស់នៅដាច់ឆ្ងាយពីសង្គម។

[6] រួមមាន បញ្ហាសុខភាព សេដ្ឋកិច្ច រដ្ឋបាល អប់រំ និងបញ្ហាផ្លូវចិត្ត ដែលគ្រួសារក្រីក្រជួបប្រទះ។

ចូលរួមសកម្មភាពអភិវឌ្ឍន៍ក្នុងសហគមន៍ ដើម្បីទទួលបានការរស់នៅមួយប្រកបដោយសុខដុមរមនីយកម្ម និងសេចក្តីថ្លៃថ្នូរ ហើយថែមទាំងយល់ពីតម្លៃនៃការអប់រំរបស់កូន និងខិតខំស្វែងរកធនធាន ដើម្បីអាចបញ្ជូនកូនឱ្យទៅរៀនបានទៀងទាត់តាមគោលបំណង។ លើសពីនេះទៀតការងារនេះ បានកាត់បន្ថយការរើសអើងចំពោះអ្នកក្រីក្រ និងជនងាយរងគ្រោះ (ស្ត្រីមេម៉ាយ កុមារជាមេគ្រួសារ អ្នកផ្ទុកមេរោគអេដស៍ និងជនពិការ) ពីសំណាក់ប្រជាជនក្នុងសហគមន៍ និងអាជ្ញាធរមូលដ្ឋានផងដែរ។

នៅក្នុងឆ្នាំ២០១៤នេះ សមាគមគ្រួសារយើង បានអនុវត្តការងារប្រឹក្សាយោបល់ជាមួយគ្រួសារគោលដៅចំនួន ២,១៩១ គ្រួសារ ខេត្តគោលដៅចំនួន២ខេត្តៈ ខេត្តកំពង់ចាម មានចំនួន១,១៥៩គ្រួសារ និងខេត្តសៀមរាបមានចំនួន១,០៣២គ្រួសារ) ហើយយើងបានទទួលនូវលទ្ធផលសំខាន់ៗដូចខាងក្រោមៈ

- តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់សមាគមគ្រួសារយើងរួមជាមួយនឹងអ្នកស្ម័គ្រចិត្តភូមិ(ធ្វើការប្រឹក្សាយោបល់ ធ្វើការតាមដាន ផ្តល់ការគាំទ្រផ្សេងៗ និងរៀបចំកិច្ចប្រជុំដោះស្រាយបញ្ហាប្រចាំខែ) គ្រួសារចំនួន១,៨៩១ (៨៦,៣%) នៃគ្រួសារសរុបចំនួន ២,១៩១ បានបញ្ចប់ការទទួលការប្រឹក្សាយោបល់ទាំង៥ជំហាន ហើយពួកគាត់មានភាពជឿជាក់លើខ្លួនឯងនិងមានភាពម្ចាស់ការ ចេះរៀបចំផែនការអភិវឌ្ឍន៍គ្រួសារខ្លួនច្បាស់លាស់ ក្លាហានចូលរួមក្នុងសកម្មភាពអភិវឌ្ឍសហគមន៍ផ្សេងៗ និងចេះទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានដើម្បី ទទួលបានសេវាកម្មផ្សេងៗមកប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហា។ ជាពិសេស ករណីអំពើហិង្សាក្នុង គ្រួសារក្នុងតំបន់ការងារត្រូវបានកាត់បន្ថយបានចំនួន៩៧,២% ។ ជាមួយគ្នានេះដែរ មានគ្រួសារចំនួន៣០០ (ខេត្តកំពង់ចាមចំនួន១៥០ និងសៀមរាបចំនួន១៥០) ដែលស្មើនឹង (១៣,៦៩%) ផ្សេងទៀត ស្ថិតក្នុងដំណើរការប្រឹក្សាយោបល់ជំហានទី៣ ដល់ជំហានទី៥។ហើយពួកគាត់ត្រូវការការគាំទ្របន្ថែមទៀត ដើម្បីអាចមានមានទំនុកចិត្ត និងភាពម្ចាស់ការក្នុងការលើកស្ទួយស្ថានភាពជីវភាពរបស់គ្រួសារឱ្យរស់នៅប្រកបដោយភាពថ្លៃថ្នូរ ។
- តាមរយៈកិច្ចប្រជុំនានាជាមួយអាជ្ញាធរមូលដ្ឋាន ការផ្តល់វគ្គបណ្តុះបណ្តាល និងវេទិកាសហគមន៍ (ដោយមានការចូលរួមពីប្រជាជន និងអាជ្ញាធរមូលដ្ឋាន) អាជ្ញាធរមូលដ្ឋានបានយល់ដឹងពីតម្រូវការ ពីបញ្ហា របស់ប្រជាជនក្រីក្រ ក្រុមជនងាយរងគ្រោះ ស្ត្រី កុមារ និងជាពិសេសបញ្ហាជនពិការ ក៏ជាផ្នែកមួយនៅក្នុងការងារអភិវឌ្ឍន៍សង្គមដែរ។ ពួកគាត់ បានបញ្ចូលតម្រូវការ និងបញ្ហាទាំងនោះ ទៅក្នុងផែនការវិនិយោគឃុំ ដើម្បីផ្តល់ឱ្យប្រជាជនក្នុងសហគមន៍ ទាំងអ្នកមាន ទាំងអ្នកក្រីក្រ ក្រុមជនងាយរងគ្រោះ ស្ត្រី កុមារ និងជនពិការ ទទួលបាននូវសេវាកម្មអភិវឌ្ឍនានា ប្រកបដោយសមធម៌។
- គ្រួសារយើងបានបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពដល់ អាជ្ញាធរមូលដ្ឋាន អ្នកស្ម័គ្រចិត្តភូមិ និងអ្នកពាក់ព័ន្ធ (សម្រាប់ខេត្តសៀមរាបនិងត្បូងឃ្មុំ) ចំនួន ១៣១នាក់(ស្រី៦៦នាក់)ស្តីពីមូលដ្ឋានគ្រឹះនៃការប្រឹក្សាយោបល់ សិទ្ធិមនុស្ស សិទ្ធិកុមារ សិទ្ធិជនពិការ។ យើងសង្កេតឃើញថា ៩៥% នៃពួកគាត់បានយល់ដឹង អនុវត្ត និងផ្សព្វផ្សាយបន្តដល់អ្នកដទៃទៀតផង។ ចំណែក៥%ទៀតក៏កំពុងបានអនុវត្តជាបន្តបន្ទាប់ដែរ។

- ដើម្បីដោះស្រាយបញ្ហាបន្ទាន់របស់គ្រួសារដៃគូ ក្រុមការងារគម្រោងបានកំណត់ការប្រជុំករណីពិបាកប្រចាំខែ ជាទៀងទាត់ជាជំនួយក្នុងការដោះស្រាយបញ្ហាធ្ងន់ធ្ងរចំនួន៤៣ក្នុងចំណោម៤៤ករណីបានលើកឡើង (មានជំងឺគ្រោះថ្នាក់ចរាចរណ៍បានឆ្លើយតបទាន់ពេលក្នុងការសង្គ្រោះអាយុជីវិត ព្រមទាំងលើកទឹកចិត្ត)។ ករណីទាំងនោះបានអន្តរាគមន៍ និងកិច្ចសហការដោះស្រាយជាមួយអាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវាសាធារណៈ និងអង្គការមិនមែនរដ្ឋាភិបាល។
- ការបញ្ចូលជនពិការចូលទៅក្នុងសកម្មភាពអភិវឌ្ឍ ពិតជាសំខាន់បំផុត ដើម្បី ឆ្លើយតបទៅនឹងការលើកស្ទួយជនពិការ ឱ្យទទួលបានសិទ្ធិរបស់ពួកគាត់។ សមាគមគ្រួសារយើងបានចងក្រងក្រុមជនពិការបានចំនួន២ដើម្បីឱ្យសម្លេងរបស់ជនពិការមានក្នុងការអភិវឌ្ឍមូលដ្ឋាន និងត្រូវបានលើកឡើងនៅក្នុងសហគមន៍ និងបានចងក្រងបណ្តាញជនពិការចំនួន២ក្រុមមានសមាជិកជាអ្នកពិការចំនួន៤៤នាក់(ស្រី១៩នាក់)ជាតំណាងឱ្យជនពិការក្នុងតំបន់ការងារ។
- បន្តការចែកផ្សាយឯកសារគម្រូ "*ពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់គ្រួសារ សម្រាប់អនុវត្តវិធីសាស្ត្រក្នុងការធ្វើការងារជាមួយនឹងគ្រួសារក្រីក្របំផុត និងក្រុមងាយរងគ្រោះបំផុតនៅក្នុងសហគមន៍នានារបស់ប្រទេសកម្ពុជា*" ដល់បណ្តាញអង្គភាពរដ្ឋ និងអង្គការដៃគូនានា និងរៀបចំសិក្ខាសាលាផ្សព្វផ្សាយថ្នាក់ជាតិស្តីពីគម្រូដោគជ័យនេះនៅខែឧសភាឆ្នាំ២០១៤ ដែលមានអ្នកចូលរួមសរុប ១០៧ នាក់ (ស្រី៤២នាក់)មកពីស្ថាប័នរដ្ឋ និង អង្គារដៃគូជាតិ-អន្តរជាតិ។ ក្រោយពីសិក្ខាសាលាផ្សព្វផ្សាយ មានអង្គការដៃគូ (អង្គការ World Vision Cambodia, អង្គការអភិវឌ្ឍសហគមន៍, Child Fund Cambodia និង Salalungkon University)មកសុំឱ្យសមាគមគ្រួសារយើងចែក រំលែកបទពិសោធ និងធ្វើទស្សនៈកិច្ចសិក្សានៅក្នុងតំបន់គោលដៅផ្ទាល់។

## ស្ថិតិគ្រួសារដៃគូទទួលបានការប្រឹក្សាយោបល់

| ខេត្ត គោលដៅ | ចំនួនគ្រួសារទទួលបានការប្រឹក្សាទាំង៥ ជំហាន | ចំនួនគ្រួសារទទួលបានការប្រឹក្សាយោបល់ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | **ជំហាន ទី១** | **ជំហាន ទី២** | **ជំហាន ទី៣** | **ជំហាន ទី៤** | **ជំហាន ទី៥** | |
| កំពង់ចាម | ១,០០៩ | ០ | ០ | ៨០ | ៦៥ | ៥ | ១,១៥៩ |
| សៀមរាប | ៨៨២ | ០ | ០ | ១១៤ | ៣៦ | ០ | ១,០៣២ |
| **សរុប** | **១,៨៩១** | **០** | **០** | **១៩៤** | **១០១** | **៥** | **២,១៩១** |

## បញ្ហាប្រឈម

- ការធ្វើចំណាកស្រុករបស់គ្រួសារក្រីក្រ។
- ការប្រឹក្សាជាមួយគ្រួសារមានអំពើហឹង្សាមានរយៈពេលយូរ និងពិបាកដោះស្រាយឱ្យទទួលបានជោគជ័យ។

## ដំណោះស្រាយ

- បន្តការប្រឹក្សាជាមួយគ្រួសារ និងសមាជិកគ្រួសារដែលនៅផ្ទះ និងរៀបចំតារាងពេលវេលាធ្វើការជាថ្មីដើម្បីអាចធ្វើការប្រឹក្សាយោបល់ នៅពេលដែលពួកគាត់ត្រឡប់មកវិញ។
- ទាមទារការប្រឹក្សារយោបល់បានញឹកញាប់ ទាំងប្ដីប្រពន្ធ និងគ្រប់សមាជិកគ្រួសារទាំងអស់ និងមានកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ។

## ចំណុចខ្លាំង

- បុគ្គលិកសង្គមមានជំនាញប្រឹក្សាយោបល់ច្បាស់លាស់ ចេះសហការគ្នាបានល្អ និងឧស្សាហ៍ព្យាយាមក្នុងការងារចុះជួយគ្រួសារដៃគូនៅថ្នាក់មូលដ្ឋាន។
- ការប្រឹក្សាយោបល់មានប្រសិទ្ធភាពខ្ពស់ ក្នុងការបង្កើនភាពជឿជាក់របស់មេគ្រួសារដៃគូ ឱ្យចេះសហការគ្នាក្នុងការលើកកម្ពស់លក្ខខណ្ឌរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ឱ្យប្រសើរឡើង។

## មេរៀនបទពិសោធន៍

- ការប្រឹក្សាយោបល់ត្រូវតែមានការចូលរួមពីសមាជិកគ្រួសារដៃគូ (ទាំងប្ដី ប្រពន្ធ និងកូន) និងការគាំទ្រពីកម្មវិធីផ្សេងៗ ដូចជា ការអភិវឌ្ឍន៍ជីវភាពរស់នៅ ការលើកស្ទួយសុខភាព និងការបណ្តុះបណ្តាលវិជ្ជាជីវៈ (ដែលមានរៀបរាប់នៅវគ្គបន្ទាប់)
- កិច្ចសហការល្អ និងការកសាងបណ្តាញទំនាក់ទំនងរឹងមាំជាមួយអាជ្ញាធរមូលដ្ឋាន ស្ថាប័នជំនាញ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត អាចជួយដោះស្រាយបញ្ហារបស់គ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះ បានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់។
- ការបញ្ចូលសកម្មភាពនានារបស់គម្រោងទៅក្នុងផែនការវិនិយោគឃុំ គឺជាការធានានូវចីរភាពគម្រោង។
- ធ្វើការជាមួយគ្រួសារក្រីក្រ និងងាយរងគ្រោះទាមទារបុគ្គលិកមានជំនាញ ចំណេះដឹង និងការអំណត់ព្យាយាម ព្រមទាំងមានការលះបង់ខ្ពស់ ដើម្បីឈានទៅរកការផ្លាស់ប្តូរផ្នត់គំនិត និងអភិវឌ្ឍគ្រួសារបានប្រកបដោយជោគជ័យ។





## ៤.៣.២. ការអភិវឌ្ឍន៍ជីវភាពគ្រួសារ

ការលើកស្ទួយសេដ្ឋកិច្ចគ្រួសារក្រីក្រពិតជាសំខាន់ខ្លាំងណាស់ក្នុងការស្តារស្ថានភាពពួកគាត់ឱ្យចាកផុតពីភាពក្រីក្របាន។ សមាគមគ្រួសារយើងបានបញ្ចូលកម្មវិធីនេះទៅក្នុង***គម្រោងពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់គ្រួសារ*** គឺដើម្បីជួយឱ្យគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះបំផុតមានលទ្ធភាពបង្កើនកម្រិតប្រាក់ចំណូលប្រចាំថ្ងៃច្រើនជាងមុន សម្រាប់បំពេញតម្រូវការចាំបាច់ក្នុងគ្រួសារ។ សមាគមគ្រួសារយើងបាន អនុវត្តការងារនេះជាមួយគ្រួសារដៃគូចំនួន១,១៥៩គ្រួសារ ក្នុងខេត្តកំពង់ចាម និងចំនួន១,០៣២គ្រួសារក្នុងខេត្តសៀមរាប។

ដោយមានកិច្ចសហការល្អជាមួយមន្ទីរកសិកម្មខេត្ត ការិយាល័យកសិកម្មស្រុក ពេទ្យសត្វភូមិ (៤២នាក់/ស្រី៤នាក់) អាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូផ្សេងៗ យើងបានដាក់ឱ្យអនុវត្តសកម្មភាពសំខាន់ៗដូចជាការផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនិងមិនមែនកសិកម្ម ការផ្តល់ការគាំទ្រផ្នែកសម្ភារ[7](រួមទាំងដើមទុន) ដំណើរការថ្នាក់អក្ខរកម្មក្នុងសហគមន៍ ការបង្កើតហាងលក់ផលិតផលកសិកម្ម ការបង្កើតក្រុមសន្សំប្រាក់ និងរៀបចំវេទិកាសាធារណៈស្តីពីការលើកកម្ពស់ការងារកសិកម្ម និងការបង្កើនប្រាក់ចំណូល[8]។ តាមរយៈការអនុវត្តន៍សកម្មភាពខាងលើយើងទទួលបានលទ្ធផលដូចខាងក្រោម៖

- ក្នុងឆ្នាំ២០១៤នេះ កិច្ចអន្តរាគមន៍របស់សមាគមគ្រួសារយើង បានជួយគ្រួសារក្រីក្រចំនួន១,៤៨៩ គ្រួសារ (៧៨.៧៧%) នៃចំនួនគ្រួសារក្រីក្របំផុត និងក្រុមជនងាយរងគ្រោះចំនួន១,៨៩១ ឱ្យចាកផុតពីភាពក្រីក្រ (យោងតាមទិន្នន័យរបស់ក្រុមប្រឹក្សាឃុំ ក្នុងតំបន់គោលដៅរបស់គម្រោង)។ សកម្មភាពសំខាន់ដែលសម្រេចបាន ផ្នែកលើកកម្ពស់ជីវភាពគ្រួសារ។
- គ្រួសារចំនួន ២,១៩១ បានទទួលការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និងជំនាញផ្សេងៗ រីឯគ្រួសារដែលបានទទួលការគាំទ្រផ្នែកសម្ភារៈ និងដើមទុនមាន ៥៧៨គ្រួសារ។ បច្ចុប្បន្ន គ្រួសារចំនួន១,៨១១ (៨២.៨១%) មានលទ្ធភាពបង្កើនផលិតភាពកសិកម្ម និងមានស្បៀងគ្រប់គ្រាន់អាចផ្គត់ផ្គង់តម្រូវការគ្រួសារបានពេញមួយឆ្នាំ ហើយបានពង្រីកមុខរបរផ្សេងៗ (ច្រើនជាង១មុខរបរ) និងអាចរកប្រាក់ចំណូលច្រើនជាងមុនដើម្បីផ្គត់ផ្គង់តម្រូវការចាំបាច់ក្នុងគ្រួសារជាពិសេសផ្គត់ផ្គង់ការសិក្សារបស់កូនៗ។ គ្រួសារចំនួន៤៥១គ្រួសារ (៤០.៤៥%) ផ្សេងទៀត សមាគមគ្រួសារយើង នឹងបន្តផ្តល់ការគាំទ្រដល់គ្រួសារទាំងនោះ ដើម្បីឱ្យពួកគេអាចពង្រីកប្រភពរកប្រាក់ចំណូលច្រើនជាងមុន និងលើកស្ទួយជីវភាពរស់នៅបានប្រសើរឡើងនាពេលអនាគត។
- បណ្តុះបណ្តាលបច្ចេកទេសផ្នែកកសិកម្មចិញ្ចឹមជ្រូក មាន់ចំនួន ១៩៦ នាក់ ស្រី ១២០ នាក់។ ផ្តល់ការគាំទ្រថវិកាគាស់គល់ ២៨៣ គ្រួសារ ផ្ទៃដីសំអាតបាន ១៤.០៥៨ ហិកតា។ ផ្តល់ទុនខ្នាតតូចដល់គ្រួសារដៃគូសម្រាប់អភិវឌ្ឍជីវភាពគ្រួសារចំនួន ២២៣គ្រួសារ ក្នុងនោះមានចិញ្ចឹមមាន់ ១៣៥គ្រួសារ ជ្រូក៦៤គ្រួសារអាជីវកម្ម២៤គ្រួសារ។
- សហការជាមួយមន្ត្រីកសិកម្មស្រុកដឹកនាំការប្រជុំពេទ្យសត្វភូមិ ផ្សព្វផ្សាយពីបច្ចេកទេសចិញ្ចឹមសត្វប្រកបដោយប្រសិទ្ធភាពដល់សហគមន៍ ចំនួន៤៤ភូមិ មានអ្នកចូលរួម ២,២៣៧ នាក់ ស្រី ១,៣៦៩នាក់ និងបានពង្រឹងការផ្តល់វ៉ាក់សាំង និងសេវាព្យាបាលសត្វ (គោនិងក្របីបានចំនួន ៣,៩៩១ ក្បាល ជ្រូក បានចំនួន៥,៧៨៨ក្បាល មាន់ ៥៣៦ក្បាល)។

---

[7]សម្ភារអនាម័យ ពូជសត្វ ពូជបន្លែ និងដើមទុន (ពី ២០ ទៅ ៧០ ដុល្លារអាមេរិក) សម្រាប់ចាប់ផ្តើមធ្វើអាជីវកម្មខ្នាតតូច (ជាលក្ខណៈគ្រួសារ)។

[8]មានការចូលរួមពីគ្រួសារកសិករក្រីក្រ អ្នកផ្តល់សេវាកសិកម្ម អ្នកផ្គត់ផ្គង់នៅទីផ្សារ និងអ្នកពាក់ព័ន្ធផ្សេងទៀត។

- ពង្រឹងក្រុមផលិតមានចំនួន ៧៨ក្រុម (សៀមរាបៈ៤៥ក្រុម និង កំពុងចាម/ត្បូងឃ្មុំ: ៣៣ក្រុម) ដែលមានសមាជិកសរុបចំនួន ៧០៥នាក់ ស្រី៥១៧នាក់ (មានក្រុមចិញ្ចឹមមាន់៤៥ ចិញ្ចឹមជ្រូក២០ ដាំបន្លែ៩ ជាល៤) ដែលចំនួនគណៈកម្មការដឹកនាំ និងសមាជិកមួយចំនួនចូលរួមប្រជុំ ៨៦០នាក់ ស្រី ៥៧០ នាក់។ ឆ្លុះបញ្ចាំងពីក្រុមផលិត (សមិទ្ធិផល ការលំបាក ដំណោះស្រាយ ផែនការបន្ត) ចំនួន ៣លើក មានសមាជិកក្រុមផលិតចំនួន ៣២៣ នាក់ ស្រី ២៣៦នាក់ ដើម្បីជម្រុញការផលិតបានកើនឡើង និងការលក់ផលិតពីសហគមន៍ទៅទីផ្សារបានទូលំទូលាយ។ក្នុងនោះ សមាគមគ្រួសារយើងមានហាងលក់ផលិតផលសម្រប់ប្រមូទិញផលិតផលមិនមែនកសិកម្ម សិប្បកម្ម មកលក់និងផ្សព្វផ្សាយ និងជាពិសេសភ្ជាប់ទំនាក់ទំនងពីអ្នកបញ្ជាទិញ ទៅអ្នកផលិតនៅឯសហគមន៍ផ្ទាល់។
- ក្រុមសន្សំប្រាក់មានចំនួន ៧១ ក្រុម (សៀមរាបៈ៤៥ក្រុម និង កំពុងចាម/ត្បូងឃ្មុំ: ២៦ក្រុម) មានសមាជិកសរុបចំនួន ៧៤២ នាក់ ស្រី ៥៦២ នាក់។ ក្នុងរយៈពេល១ឆ្នាំ មានសមាជិកសន្សំសរុប ១,៩១៣ នាក់ ស្រី១,៣៩៥ នាក់ ដែលមានទឹកប្រាក់សរុបចំនួន ៧១,៤៨១,៤០០ រៀល (១៧,៨៧០.៣៥ ដុល្លា)។ បណ្តុះបណ្តាលពីរបៀបកត់ត្រា(ខ្ចី សន្សំ និងរបាយការណ៍) និងការគ្រប់គ្រងក្រុមសន្សំប្រាក់ទាំងពីរខេត្តមាន អ្នកចូលរួមដែលជាតំណាងមកពីក្រុមទាំង ៧១ ក្រុម ចំនួន ១៤២ នាក់ ស្រី ៩០ នាក់។ ដើម្បីជួយសម្រួលការអាន ការសរសេរ ការគិតលេខ និងដើម្បីប្រកបរបរចិញ្ចឹមជីវិតល្អចាំបាច់ត្រូវចេះ ដូច្នេះយើងបានបើកថ្នាក់អក្ខរកម្មចំនួន១៦ ថ្នាក់មានសិស្សចំនួន ២៤៨នាក់ ស្រី១៩១នាក់។ ក្រោយពីការរៀសូត្របានចេះដឹង ពួកគាត់បានយកចំណេះទៅប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ។
- សមាគមគ្រួសារយើងបានបណ្តុះបណ្តាលជំនាញផ្សេងៗមិនមែនកសិកម្មចំនួន៥០គ្រួសារ(ធ្វើកន្ត្រកផ្លែឈើ ធ្វើនំខ្មែរ និងទឹកសណ្តែក)។ ជំនាញនេះបានធ្វើឱ្យគ្រួសារដៃគូទាំងនោះបានបង្កើន ប្រាក់ចំណូលបន្ថែមទៀតសម្រាប់គ្រួសារ ។

| ខេត្ត គោលដៅ | ចំនួនគ្រួសារទទួលបានការគាំទ្រផ្នែកបណ្តុះបណ្តាល ( សរុប ចំនួន ៣,០៤៩ គ្រួសារ ) * | | | | | | | | | | ចំនួនគ្រួសារទទួលបានការគាំទ្រផ្នែកសម្ភារនិងដើមទុន |
|---|---|---|---|---|---|---|---|---|---|---|---|
| | ការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម | | | | | | ការបណ្តុះបណ្តាលជំនាញផ្សេងៗ (មិនមែនកសិកម្ម) | | | | |
| | ចិញ្ចឹមសត្វ | ដាំដុះបន្លែ | បណ្តុះផ្សិត | ការធ្វើស្រែប្រពលវប្បកម្ម | ធ្វើជីកំប៉ុស្តិ៍ | ការទុកដាក់និងការកែច្នៃផលិតផលកសិកម្ម | តម្បាញ | ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ | ថ្នាក់អក្ខរកម្ម | ការកត់ត្រានិងចុះបញ្ជីក្នុងសៀវភៅក្រុមសន្សំប្រាក់ | |
| កំពង់ចាម | ៨៧ គ្រួសារ | ២៩ គ្រួសារ | 0 | 0 | ២២ គ្រួសារ | 0 | ៣៦ គ្រួសារ | ៧៦១គ្រួសារ | ១០១ នាក់ | ៥២គ្រួសារ | ៣៩៧ |
| សៀមរាប | ៥០៤ គ្រួសារ | ៨៤ គ្រួសារ | ៩ គ្រួសារ | ៧៣ គ្រួសារ | ១៥ គ្រួសារ | ១០៤ គ្រួសារ | ៨៧ គ្រួសារ | ៥០៤ គ្រួសារ | ១០៩ នាក់ | ៩០ គ្រួសារ | ៥២៤ គ្រួសារ |
| **<u>សរុប</u>** | **៥៩១** | **១១៣** | **៩** | **៧៣** | **៣៧** | **១០៤** | **១២៣** | **១,២៦៥** | **២១០** | **១៤២** | **៩២១** |

* គ្រួសារមួយ ទទួលបានការបណ្តុះបណ្តាលច្រើនជាង ២

ការខិតខំប្រឹងប្រែងរបស់ក្រុមប្រតិបត្តិការគម្រោង (ក្រុមការងារប្រឹក្សាយោបល់ និងក្រុមការងារអភិវឌ្ឍន៍ជីវភាពគ្រួសារ) បានសម្រេចសមិទ្ធផលទាំងអស់ខាងលើនេះ ហើយធ្វើឱ្យគ្រួសារដៃគូមានកម្លាំងចិត្ត និងជួយឱ្យពួកគាត់មានភាពជឿជាក់លើខ្លួនឯងក្នុងការលើកស្ទួយជីវភាពរស់នៅប្រសើរឡើងនិងឈានទៅបង្កើតផែនការអភិវឌ្ឍន៍គ្រួសារ តាមរយៈផែនការសម្រាប់ការអភិវឌ្ឍន៍ជីវភាពរបស់គ្រួសារដៃគូ និងការផ្តល់ការគាំទ្រផ្នែកបណ្តុះបណ្តាលបច្ចេកទេសផ្សេងៗ និងការគាំទ្រផ្នែកសម្ភារ (ព្រមទាំងធ្វើការតាមដាន) ធ្វើឱ្យពួកគាត់មានការអភិវឌ្ឍជីវភាពគ្រួសារ និងរស់នៅប្រកបដោយសុខដុមរមនា។

**<u>បញ្ហាប្រឈម</u>**

- តំបន់គោលដៅក្នុងស្រុកអង្គរជុំ ខេត្តសៀមរាប ខ្វះទឹកប្រើប្រាស់ប្រចាំថ្ងៃ និងមិនអាចដាំដំណាំបានក្នុងរដូវប្រាំង។
- គ្រោះធម្មជាតិ (ទឹកជំនន់ រាំងស្ងួត ព្យុះនិងរន្ទះ)
- ជំងឺរាតត្បាតលើបន្លែ និងសត្វចិញ្ចឹមរបស់គ្រួសារដៃគូ។
- ដីពិបាកធ្វើដំណាំកសិកម្ម(ដីដាំដុះសម្បូរដំបូកគល់ឈើ និងខ្សោះជីជាតិ)។
- ប្រជាជនប្រើប្រាស់ថ្នាំពុលកសិកម្ម ជីគីមី (សម្លាប់សត្វល្អិត និងស្មៅ )។

**<u>ដំណោះស្រាយ</u>**

- ប្រឹក្សាឱ្យគ្រួសារជីកអណ្តូង/ស្រះទឹក និងប្រើបច្ចេកទេសកសិកម្មថ្មី ព្រមទាំងដាំប្រភេទដំណាំធន់កំដៅនិងប្រើទឹកតិច។
- បណ្តុះបណ្តាលពីវិធានការត្រៀមបង្ការ និងបន្សាំទៅនឹងគ្រោះធម្មជាតិ ដល់គ្រួសារដៃគូ។
- សហការជាមួយនឹងពេទ្យសត្វភូមិ និងការិយាល័យកសិកម្មស្រុក ការិយាល័យផលិតកម្ម និងបសុព្យាបាលស្រុក/ខេត្ត (ដើម្បីចាក់វ៉ាក់សាំង និងព្យាបាលជំងឺ) តាមដាន និងពង្រឹងបន្ថែមពីការសត្វចិញ្ចឹមសត្វរបស់គ្រួសារដៃគូ។
- ផ្តល់ការគាំទ្រការគាស់គល់/សម្អាតដី (សម្រាប់កែប្រែគុណភាពដី)។
- ផ្សព្វផ្សាយឱ្យគាត់យល់ពីផលប៉ះពាល់និងគ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំពុល ជីគីមី ដោយប្តូរមកប្រើថ្នាំនិងជីធម្មជាតិវិញ(បណ្តុះបណ្តាលពីរបៀបផលិតជីកំប៉ុស្ត៍)។

## ចំណុចខ្លាំង

- បុគ្គលិកផ្នែកអភិវឌ្ឍជីវភាពគ្រួសារសហការជាមួយបុគ្គលិកផ្នែកសង្គម (ផ្នែកប្រឹក្សាយោបល់) ពូកែស្វែងរកភាពខ្លាំង (ជំនាញកសិកម្មនានា) ដែលគ្រួសារដៃគូមាន ហើយចេះផ្តល់ជំនាញកសិកម្ម សមស្របទៅនឹងស្ថានភាពភូមិសាស្ត្រ (ដី និងអាកាសធាតុ) និងតម្រូវការទីផ្សារដល់គ្រួសារដៃគូ ។
- ជំនាញកសិកម្មដែលសមាគមគ្រួសារយើងផ្តល់ឱ្យគ្រួសារដៃគូ មានភាពសម្បូរបែប រួមជាមួយនឹងការគាំទ្រផ្នែកសម្ភារជួយឱ្យគ្រួសារដៃគូ អាចបង្កើនប្រភពប្រាក់ចំណូលបានប្រកបដោយប្រសិទ្ធភាព។

## មេរៀនបទពិសោធន៍

- មានកិច្ចសហការល្អជាមួយមន្ទីរកសិកម្មខេត្ត ការិយាល័យកសិកម្មស្រុក និងពេទ្យសត្វភូមិ អាចជួយដោះស្រាយបញ្ហាប្រឈមនានា (ជំងឺរាតត្បាតលើបន្លែ និងសត្វចិញ្ចឹម ដែលគ្រួសារដៃគូជួបប្រទះ)បានប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។
- ការបង្កើនកម្រិតជីវភាពគ្រួសារក្រីក្រ គ្រួសារងាយរងគ្រោះ និងគ្រួសារដែលផ្តាច់ខ្លួនចេញពីសង្គម គឺត្រូវដោះស្រាយបញ្ហាឱ្យចំទៅនឹងតម្រូវការជាក់ស្តែង និងពិតប្រាកដ ដែលកើតចេញពីការវិភាគជាមួយគ្នា (រវាងគ្រួសារដៃគូ និងបុគ្គលិកគ្រួសារយើង) ដោយមិនប្រថុយប្រថាន ក្នុងកំឡុងពេលនៃការប្រឹក្សាយោបល់។



មីងគង់ ត្រើច រស់នៅភូមិតាប្រុក ឃុំលាងដៃ ស្រុកអង្គរ ធំ ខេត្តសៀមរាប ប្រកបរបរលក់គ្រឿងទេសសម្រាប់ចិញ្ចឹមជីវិតបានសមរម្យ។



មីង ថៅ ហ៊ាត រស់នៅភូមិក្លូង ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប ប្រកបរបរបណ្តុះផ្សិតចំបើង។





កម្មភាពដាំដំណាំរបស់អ្នកស្រី សឿន យ៉ាន ជាគ្រួសារដៃគូរស់នៅភូមិ គោកស្រឡៅ ឃុំចុងដាច ស្រុកតំបែរ ខេត្តកំពង់ចាម។

ក្រុមត្បាញជាលនៅភូមិ គោកកក់ ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប។



## ៤.៣.៣. ការលើកស្ទួយសុខភាពគ្រួសារ

ដើម្បីលើកកម្ពស់សុខភាពគ្រួសារ និងសហគមន៍ឱ្យប្រសើរឡើង គម្រោងពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់គ្រួសារ របស់សមាគមគ្រួសារយើង បាននិងកំពុងអនុវត្តសកម្មភាពលើកស្ទួយសុខភាពគ្រួសារចាប់តាំងពីឆ្នាំ២០០៧រហូតមកដល់បច្ចុប្បន្ន។ នៅក្នុងឆ្នាំ ២០១៤នេះ សមាគមគ្រួសារយើងបានអនុវត្តសកម្មភាពនេះជាមួយគ្រួសារក្រីក្រ និងក្រុមងាយរងគ្រោះបំផុតសរុប ចំនួន២,១៩១គ្រួសារដៃគូ ដែលគ្រួសារដៃគូចំនួន១,០៣២ នៅក្នុងខេត្តសៀមរាប និងចំនួន ១,១៥៩គ្រួសារដៃគូ នៅខេត្តកំពង់ចាម ហើយគ្រួសារមិនមែនដៃគូមានចំនួន ៥,៨៥៤គ្រួសារ ដែលមានចំនួន៤,១៧០ គ្រួសារ នៅខេត្តសៀមរាប និង ១,៦៨៤ គ្រួសារនៅខេត្តកំពង់ចាម។

| ខេត្ត គោលដៅ | ស្រុក គោលដៅ | ឃុំ គោលដៅ | ភូមិ គោលដៅ | ការិយាល័យ ប្រតិបត្តិ ស្រុក | មណ្ឌល សុខភាព | ក្រុមទ្រទ្រង់សុខភាពភូមិ | គ្រួសារដៃគូ | គ្រួសារ មិន មែនដៃគូ |
|---|---|---|---|---|---|---|---|---|
| សៀមរាប | ២ | ៨ | ២៥ | ២ | ៧ | ៥០ (៣២ ស្រី) | ១,០៣២ | ៤,១៧០ |
| កំពង់ចាម | ២ | ៨ | ១៩ | ២ | ៧ | ៣៣ (២៩ ស្រី) | ១,១៥៩ | ១,៦៨៤ |
| **សរុប** | **៤** | **១៦** | **៤៤** | **៤** | **១៤** | **៨៣ (៦១ ស្រី)** | **២,១៩១** | **៥,៨៥៤** |

ការអនុវត្តន៍ការងារលើកស្ទួយសុខភាពគ្រួសារនេះ មានគោលបំណងជួយឱ្យគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះបំផុត ទទួលបាននូវសេវាសុខាភិបាលប្រកបដោយគុណភាព ហើយយល់ដឹង និងធ្វើការអនុវត្តន៍តំហែទាំសុខភាព នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។ ក្នុងការអនុវត្តន៍ការងារនេះ សមាគមគ្រួសារយើង បានសហការជាមួយមន្ទីរ សុខាភិបាលខេត្តគោលដៅទាំង ២ ការិយាល័យប្រតិបត្តិស្រុក មណ្ឌលសុខភាព អាជ្ញាធរមូលដ្ឋាន និងជាពិសេស ក្រុមទ្រទ្រង់សុខភាពភូមិ ក្នុងតំបន់គោលដៅ រួមជាមួយអង្គការដៃគូផ្សេងទៀត ហើយទទួលបានលទ្ធផលដូចខាងក្រោម៖

- សមាគមគ្រួសារយើង សហការជាមួយមន្ត្រីរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ (ក្នុងវិស័យសុខាភិបាល) បានរៀបចំវេទិកាសុខភាពសហគមន៍ (ចូលរួមដោយអ្នកផ្តល់សេវា និងអ្នកទទួលសេវា) ចុះធ្វើការត្រួតពិនិត្យ និងកែលម្អ គុណភាពនៃសេវាសុខាភិបាលនៅថ្នាក់មូលដ្ឋាន មាន១៤មណ្ឌលសុខភាព និង៤៤ភូមិគោលដៅ ដែលបានចុះទៅជួបគ្រួសារដៃគូចំនួន ៤១៩នាក់ (ស្រី ២៨១) ដើម្បីពិនិត្យមើលសេវារបស់ខ្លួន និងកសាងទំនាក់ទំនងរវាងអ្នកផ្តល់សេវាសុខភាពនិងអ្នកទទួលសេវាទទួលទទួលសេវាសុខភាព។ ជាលទ្ធផល មន្ត្រីរដ្ឋាភិបាល ជាពិសេស មន្ត្រី ការិយាល័យស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព ប្តេជ្ញានឹងលុបបំបាត់អាកប្បកិរិយាមិនល្អរបស់មន្ត្រី សុខាភិបាលមួយចំនួនតូច និងធ្វើឱ្យប្រសើរនូវគុណភាពនៃសេវាសុខាភិបាល ផ្តល់ដោយសមធម៌ដល់ប្រជាជនក្នុងសហគមន៍ ទាំងគ្រួសារដៃគូ និងគ្រួសារមិនមែនដៃគូ ជាពិសេសគ្រួសារក្រីក្រ ក្រុមងាយរងគ្រោះ ស្ត្រីមានផ្ទៃពោះ និងកុមារ។

- តាមរយៈការងារប្រឹក្សាយោបល់ ការផ្ដល់សម្ភារអនាម័យ ការប្រជុំស្ដីពីបញ្ហាសុខភាព ការរៀបចំវេទិកាសុខភាព ទិវាអនាម័យភូមិប្រចាំត្រីមាស ៩១,១% នៃគ្រួសារដៃគូក្នុងខេត្តសៀមរាប និងកំពង់ចាម មានជំនឿចិត្តលើខ្លួនឯង និងហ៊ានសម្រេចចិត្តប្រើសេវាសុខភាពសាធារណៈពេលមានបញ្ហាសុខភាព(លើសពី៥ដងក្នុងមួយឆ្នាំ)។ ៩៥% នៃគ្រួសារដៃគូក្នុងខេត្តកំពង់ចាម និង៨៦% នៃគ្រួសារដៃគូក្នុងខេត្តសៀមរាប ផ្លាស់ប្ដូរទម្លាប់/ឥរិយាបថមកថែទាំ សុខភាព ព្រមទាំងបានយល់ដឹង និងបានអនុវត្តការថែទាំសុខភាពគ្រួសារបានល្អ(ដូចជាទៅ ពិនិត្យផ្ទៃពោះទៀងទាត់ សម្រាលកូននៅ មណ្ឌលសុខភាព ចាក់វ៉ាក់សាំងកូន រក្សាអនាម័យខ្លួនប្រាណសម្រាប់ខ្លួនឯងនិងកុមារ សម្អាតបរិស្ថានក្នុងផ្ទះនិងជុំវិញផ្ទះ គេងក្នុងមុង ប្រើប្រាស់បង្គន់អនាម័យ និងបរិភោគទឹកដាំពុះជាដើម)។
- ដើម្បីកែប្រែទម្លាប់ឱ្យគ្រួសារដៃគូអនុវត្តអនាម័យល្អ សមាគមគ្រួសាររយើងបានផ្ដល់កំសៀវទឹកចំនួន១៨០ និងធុងចម្រោះទឹកចំនួន១២៧ ដល់គ្រួសារដៃគូចំនួន៣០០គ្រួសារ (សៀមរាបៈ ១៥០គ្រួសារ និងកំពង់ចាម១៥០គ្រួសារ) ដើម្បីជម្រុញ និងលើកទឹកចិត្តដល់គ្រួសារដៃគូឱ្យពួកគាត់មានចំណេះដឹង និងផ្លាស់ប្ដូរទម្លាប់/ឥរិយាបទ អនុវត្តការថែទាំសុខភាពអនាម័យជាប្រចាំ (ដូចជា ពិនិត្យផ្ទៃពោះទៀងទាត់ សម្រាលកូននៅមណ្ឌលសុខភាព ចាក់វ៉ាក់សាំងកូន រក្សាអនាម័យខ្លួនប្រាណសម្រាប់ខ្លួនឯងនិងកុមារ សម្អាតបរិស្ថានក្នុងផ្ទះនិងជុំវិញផ្ទះ គេងក្នុងមុង ប្រើប្រាស់បង្គន់ អនាម័យ និងបរិភោគទឹកដាំពុះ/ទឹកចម្រោះជាដើម)។ ក្រៅពីនេះបុគ្គលិកសមាគមគ្រួសារយើងបានប្រឹក្សាជាមួយគ្រួសារជាប្រចាំ ដើម្បីឱ្យសមាជិកគ្រួសារគ្រប់គ្នាអនុវត្តការរស់នៅស្អាត ហូបស្អាត និងផឹកស្អាតក្នុងគ្រួសារ។

**<u>បញ្ហាប្រឈម</u>**

- មណ្ឌលសុខភាពនៅឆ្ងាយពីផ្ទះគ្រួសារដៃគូ។
- គ្រួសារដៃគូមួយចំនួនតូចនៅមានជំនឿអរូបិយ និងមានជំនឿលើគ្រូបុរាណក្នុងការព្យាបាលជំងឺ
- គ្រួសារមួយចំនួនតូចនៅមិនទាន់មានទំនុកចិត្តលើមណ្ឌលសុខភាពហើយមានទំនោរទៅប្រើប្រាស់សេវាសុខភាពឯកជន។
- គ្រួសារក្នុងសហគមន៍មិនសូវបានចូលរួមបានច្រើនពេលបុគ្គលិកសមាគមចុះផ្សព្វផ្សាយការថែទាំសុខភាព។

**<u>ដំណោះស្រាយ</u>**

- លើកបញ្ហានេះក្នុងកិច្ចប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីបញ្ចូលបញ្ហានេះក្នុងផែនការអភិវឌ្ឍន៍ឃុំ។
- បន្តធ្វើការប្រឹក្សាយោបល់ជាមួយគាត់ ដើម្បីបង្វែរផ្នត់គំនិតពួកគាត់ទៅរកការព្យាបាលវេជ្ជសាស្ត្របន្តិចម្ដងៗ។
- ប្រឹក្សាយោបល់ដល់គ្រួសារទាំងនោះ អំពីការចំណាយថវិកាតិចក្នុងការប្រើសេវាសាធារណៈនិងមិនចំណាយសោះ ចំពោះគ្រួសារក្រីក្របំផុត។
- សហការជាមួយអ្នកស្មគ្រ័ចិត្តភូមិ និងមេភូមិចលនាផ្ដល់ព័ត៌មាន និងផ្សព្វផ្សាយបន្ត ។

| ចំណុចខ្លាំង | មេរៀនបទពិសោធន៍ |
| --- | --- |
| • ការងារលើកស្ទួយសុខភាពគ្រួសារ មានការគាំទ្រពីមន្ត្រីរដ្ឋាភិបាល (មន្ត្រីមន្ទីរសុខាភិបាលខេត្ត ការិយាល័យ ប្រតិ បត្តិស្រុក និងមណ្ឌលសុខភាព) អង្គការដៃគូផ្សេងទៀត និងមានការចូលរួមពីប្រជាជនក្នុងសហគមន៍។<br>• ការអប់រំស្តីពីបញ្ហាសុខភាពនៅថ្នាក់មូលដ្ឋានដល់ប្រជាជនក្នុងសហគមន៍ សុទ្ធតែផ្តល់នូវចំណេះដឹងស្តីពីការថែទាំសុខភាពល្អៗ អាចជួយដោះស្រាយបញ្ហាសុខភាព ដែលប្រជាជនទាំងនោះកំពុងជួបប្រទះ។ | • ការសហការ និងបន្តគាំទ្រការកសាងសមត្ថភាពដល់ក្រុមទ្រទ្រង់សុខភាពភូមិ គឺជួយឱ្យពួកគាត់មានសមត្ថភាពក្នុងការកៀរគរប្រជាជនឱ្យប្រើប្រាស់សេវាសុខាភិបាលរដ្ឋដែលចំណាយតិច និងយល់ដឹង និងអនុវត្តការថែទាំសុខភាពល្អសម្រាប់គ្រួសារ ប្រកបដោយចីរភាព។<br>• ការផ្តល់ការគាំទ្រផ្នែកសម្ភារអនាម័យ (កំសៀវទឹក ឬធុងចម្រោះទឹក) បន្ថែមពីលើការអប់រំ ឬបណ្តុះបណ្តាលអំពីការថែទាំសុខភាពល្អ ជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការជួយឱ្យគ្រួសារដៃគូផ្លាស់ប្តូរផ្នត់គំនិតនិងកែប្រែទម្លាប់មកអនុវត្តការថែទាំសុខភាពក្នុងគ្រួសារបានល្អប្រសើរ។ |



បុគ្គលិកសមាគមគ្រួសារយើង សហការជាមួយមន្ត្រីមណ្ឌលសុខភាពចុះផ្សព្វផ្សាយពីការអនុវត្តសុខភាពល្អទាំង១២ចំនុចនៅឃុំលាងដៃ ស្រុកអង្គរធំ (ខេត្តសៀមរាប)



ការផ្តល់សម្ភារអនាម័យដល់គ្រួសារដៃគូនៅខេត្តកំពង់ចាម



## ៤.៣.៤. ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជន យុវនារីក្រីក្រ និងងាយរងគ្រោះអាយុ១៥-២៤ឆ្នាំដែលបោះបង់ការសិក្សា

ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ពីអង្គការភ្លែនអូស្ត្រាលី តាមរយៈអង្គការភ្លែនកម្ពុជា គម្រោង "**បណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជនយុវនារីដែលងាយរងគ្រោះ**" រយៈពេល៤ឆ្នាំ (ខែមិថុនា ឆ្នាំ២០១៣ - ខែកក្កដា ឆ្នាំ២០១៧) ត្រូវបានបង្កើតឡើង ក្នុងបំណងជួយឱ្យយុវជនក្រីក្រដែលបោះបង់ការសិក្សា (ទាំងប្រុសនិងស្រី អាយុពី ១៥ដល់២៤ឆ្នាំ) នៅក្នុងខេត្តសៀមរាប កំពង់ចាម និងរតនគីរី មានលទ្ធភាពទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប្រកបដោយគុណភាព និងឆ្លើយតបនឹងតម្រូវការទីផ្សារការងារ ជួយឱ្យពួកគេទទួលឱកាសការងារសមរម្យនិង ថ្លៃថ្នូរ[9]។ ការងារបណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជនក្រីក្រដែលបោះបង់ការសិក្សានេះ ក៏ជាសកម្មភាពមួយនៅក្នុងក្របខ័ណ្ឌនៃគម្រោង"**ពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់គ្រួសារ**"(ខែមិថុនាឆ្នាំ២០១១-ខែកក្កដាឆ្នាំ២០១៤) កំពុងអនុវត្តក្នុងខេត្តសៀមរាបនិងខេត្តកំពង់ចាម។

ក្នុងឆ្នាំ២០១៤នេះ សមាគមគ្រួសារយើង (តាមរយៈគម្រោង ទាំងពីរនេះ) បានគាំទ្រយុវជនបោះបង់ការសិក្សាសរុបចំនួន៣២២នាក់ (ស្រី២២៥នាក់)ដូចមានខ្លឹមសារក្នុងប្រអប់ខាងក្រោម៖

- ស្ថិតក្នុងក្របខ័ណ្ឌនៃគម្រោង "**ពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់គ្រួសារ**" យុវជនក្រីក្រដែលបោះបង់ការសិក្សាចំនួន៧៦នាក់ (ស្រី៥៧នាក់) បានទទួលវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្សេងៗនៅតាមសហគមន៍ និងសហគ្រាសខ្នាតតូច។ តាមរយៈការគាំទ្រសម្ភារ (រួមទាំងទុនសម្រាប់បើកអាជីវកម្ម) និងការត្រួតពិនិត្យតាមដានជាទៀងទាត់ បច្ចុប្បន្នយុវជនក្រីក្រទាំងនោះកំពុងប្រកបរបរប្រចាំថ្ងៃតាមជំនាញដែលខ្លួនមាន នៅក្នុងសហគមន៍របស់ពួកគេ ហើយអាចរកប្រាក់ចំណូលពី៥,០០០រៀល ដល់២០,០០០រៀលក្នុងមួយថ្ងៃ និង បានរួមចំណែកលើកស្ទួយជីវភាពគ្រួសាររបស់ពួកគេផងដែរ។
- ស្ថិតក្នុងក្របខ័ណ្ឌនៃគម្រោង "បណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជនយុវនារីដែលងាយរងគ្រោះ" វិញ គម្រោងបានធ្វើការបណ្តុះបណ្តាលនៅតាមសហគមន៍ សហគ្រាសខ្នាតតូច និងតាមមជ្ឈមណ្ឌលដែលបានផ្តល់ជំនាញបច្ចេកទេសផ្សេងៗដល់យុវជនក្រីក្រដែលបោះបង់ការសិក្សាចំនួន២៤៥នាក់ (ស្រី១៦៨នាក់)។ ពួកគេទាំងនោះនឹងមានលទ្ធភាពប្រកបរបរទៅតាមជំនាញដែលខ្លួនមាន បន្ទាប់ពីបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេល ៤ខែនេះ។
- សមិទ្ធផលគម្រោងនេះបានរួមចំណែកកាត់បន្ថយការចំណាកស្រុករបស់យុវជនដែលគ្មានជំនាញ និងគ្មានការងារ ព្រមទាំងបានលើកស្ទួយតួនាទីរបស់យុវជនក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសាររបស់ពួកគេផងដែរ។

សមិទ្ធផលខាងលើនេះ គឺកើតចេញពីកិច្ចខិតខំប្រឹងប្រែងរបស់បុគ្គលិកសមាគមគ្រួសារយើង ក្នុងការផ្សព្វផ្សាយ អំពីសិទ្ធិរបស់យុវជន និងឱកាសការងារសម្រាប់យុវជន ដល់ឪពុកម្តាយយុវជនដែលបោះបង់ការ

[9] ការងារផ្លូវការ និងការងារនៅក្នុងបណ្តាសហគ្រាសខ្នាតតូច(ឬហាងអាជីវកម្មខ្នាតតូច)។

សិក្សា ធ្វើការកំណត់ពីចំណង់ចំណូលចិត្តធ្វើការងាររបស់យុវជន និងជំនាញដែលយុវជនមានសមស្របតាមតម្រូវការទីផ្សារការងារ ព្រមទាំងក្នុងការជំនះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

| ល.រ | ខេត្តគោលដៅ | ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្សេងៗ | សរុប |
|---|---|---|---|
| ក្នុងក្របខ័ណ្ឌគម្រោងពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់គ្រួសារ | | | |
| ការបណ្តុះបណ្តាលធ្វើឡើងក្នុងសហគមន៍ | | | |
| ១ | កំពង់ចាម | -ភ្លេងខ្មែរមានចំនួន១ នាក់ (ស្រី0) | ១ នាក់ (ស្រី 0) |
| ការបណ្តុះបណ្តាលធ្វើឡើងនៅតាមសហគ្រាសខ្នាតតូច | | | |
| ១ | កំពង់ចាម | -ជួសជុលម៉ូតូមានចំនួន ៩ នាក់ (ស្រី 0)<br>-ផាត់មុខ-អ៊ុតសក់មានចំនួន ៧ នាក់ (ស្រី ៧ នាក់)<br>-កាត់ដេរមានចំនួន ១៤ នាក់ (ស្រី ១៤ នាក់)<br>-កាត់សក់មានចំនួន៦ នាក់ (ស្រី0) | ៣៦ នាក់ (ស្រី ២១) |
| ២ | សៀមរាប | -ជួសជុលគោយន្តមានចំនួន ២ នាក់ (ស្រី 0)<br>ផាត់មុខ-អ៊ុតសក់ ៧ នាក់ (ស្រី ៧ នាក់)<br>-កាត់ដេរមានចំនួន ២៧ នាក់ (ស្រី ២៦ នាក់)<br>-ផាត់មុខ-អ៊ុតសក់មានចំនួន ៧ នាក់ (ស្រី ៧ នាក់)<br>-សម្អាងការមានចំនួន ៣ នាក់ (ស្រី ៣) | ៣៩ នាក់ (ស្រី ៣៦) |
| | | <u>សរុប</u> | **<u>៧៦នាក់ (ស្រី ៥៧)</u>** |
| ក្នុងក្របខ័ណ្ឌគម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជនបោះបង់ការសិក្សា | | | |
| ការបណ្តុះបណ្តាលធ្វើឡើងនៅមជ្ឈមណ្ឌល | | | |
| ១ | សៀមរាប | -កាត់ដេរនារីមានចំនួន១៧ នាក់ (ស្រី១៧នាក់)<br>-តនិងតម្លើងបណ្តាញអគ្គីសនី១នាក់ (ស្រី 0)<br>-ចុងភៅមានចំនួន៣១នាក់ (ស្រី២២នាក់) | ៤៩ នាក់ (ស្រី ៣៩) |
| ២ | កំពង់ចាម | -ជួសជុសម៉ូតូមានចំនួន ១១ នាក់ (ស្រី 0 នាក់)<br>-កាត់ដេរមានចំនួន១០ នាក់ (ស្រី ៧ នាក់)<br>-អ៊ុតសក់មានចំនួន១០ នាក់ ( ស្រី ១០ នាក់) | ៣១ នាក់ (ស្រី ១៧) |
| ៣ | រតនគិរី | -កែសម្ផស្សមានចំនួន២០ នាក់(ស្រី ២០ នាក់) | ២០ នាក់ (ស្រី ២០) |
| ការបណ្តុះបណ្តាលធ្វើឡើងនៅតាមសហគ្រាស | | | |
| ១ | សៀមរាប | -ជួសជុលម៉ូតូមានចំនួន៩នាក់ (ស្រី0នាក់)<br>-ជួសជុលម៉ាស៊ីនខ្នាតតូច (គោយន្ត ម៉ាស៊ីនភ្លើង និងម៉ាស៊ីនបូមទឹក)មានចំនួន៨ នាក់ (ស្រី0នាក់)<br>-អ៊ុតសក់មានចំនួន៩នាក់ (ស្រី៩នាក់)<br>-សម្អាងការមានចំនួន៦នាក់ (ស្រី៥នាក់)<br>-កាត់ដេរមានចំនួន២នាក់ (ស្រី២នាក់)<br>-ជួសជុលទូរស័ព្ទមានចំនួន២នាក់ (ស្រី0នាក់) | ៣៦ នាក់ (ស្រី ១៦ ) |
| ២ | កំពង់ចាម | -កាត់ដេរ ១៦ នាក់ (ស្រី ១៥ នាក់)<br>-អ៊ុតសក់ ១០ នាក់ (ស្រី ១០ នាក់) | ២៩ នាក់ (ស្រី ២៥) |

| | | | |
|---|---|---|---|
| | | -ជួសជុលម៉ូតូ ២ នាក់ (ស្រី ០ នាក់)<br>-ជួសជុលទូរស័ព្ទ ១ នាក់ ( ស្រី ០ នាក់) | |
| ៣ | រតនគិរី | -ជួសជុលម៉ូតូមានចំនួន៧នាក់ (ស្រី ០នាក់)<br>-កាត់ដេរមានចំនួន៣នាក់ (ស្រី ៣នាក់) | ១០ នាក់ (ស្រី ៣) |
| **ការបណ្តុះបណ្តាលធ្វើឡើងនៅតាមសហគមន៍** | | | |
| ១ | កំពង់ចាម | -ចិញ្ចឹមមាន់ ៣០ នាក់ ( ស្រី ២១ នាក់) | ៣០ នាក់ (ស្រី២១) |
| ២ | រតនគិរី | -ការចិញ្ចឹមមាន់មានចំនួន២០ នាក់(ស្រី ១៧ នាក់) | ២០ នាក់ (ស្រី១៧) |
| | | **សរុប** | **២៤៥ នាក់ (ស្រី ១៦៨)** |

**បញ្ហាប្រឈម**

- ស្ថានភាពជីវភាពរស់នៅរបស់យុវជនយុវនារីមានភាពលំបាក (ភាពក្រីក្រ)
- ការធ្វើចំណាកស្រុករបស់យុវជនយុវនារីទៅស្រុក ឬខេត្តផ្សេង និងទៅប្រទេសជិតខាង (ថៃ)
- យុវជនយុវនារីត្រូវបានគេចាត់ទុកថាជាកម្លាំងស្នូលក្នុងការរកប្រាក់ចំណូលជួយគ្រួសារ
- ការចាប់ផ្តើមអនុវត្តគម្រោងមានភាពយឺតយ៉ាវ (ត្រីមាសទី២)

**ដំណោះស្រាយ**

- បង្កលក្ខណៈងាយស្រួលដល់យុវជនយុវនារីឱ្យទទួលបានជំនាញជាក់លាក់ និងការងារសមរម្យ ឬបើកអាជីវកម្មខ្នាតតូចដោយខ្លួនឯង
- ផ្តល់ប្រឹក្សាយោបល់ដល់យុវជនយុវនារី និងគ្រួសាររបស់គេឱ្យយល់ពីតម្លៃនៃជំនាញវិជ្ជាជីវៈ ប្រសើរជាងការធ្វើចំណាកស្រុកគ្មានជំនាញ និងដោយប្រថុយប្រថាន។
- សហការជាមួយអជ្ញាធរមូលដ្ឋានដើម្បីផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងពីគម្រោងដល់យុវជនយុវនារី និងប្រជាពលរដ្ឋមូលដ្ឋាន។





សកម្មភាពជួសជុសម៉ូតូ និងម៉ាស៊ីនខ្នាតតូច

## ចំណុចខ្លាំង

- យុវជនយុវ៉ានារី និងឪពុកម្តាយមួយចំនួនយល់ពីតម្លៃ និងអត្ថប្រយោជន៍នៃជំនាញវិជ្ជាជីវៈ និងបានលះបង់ពេលវេលាចូលរួមរៀនសូត្រ ជាមួយគម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈរហូតដល់ចប់វគ្គ និងទទួលបានជោគជ័យ។
- ជំនាញប្រឹក្សាយោបល់គឺជាកម្លាំចលករដ៏សំខាន់ក្នុងការបង្ខិតជិត និងបង្កើនភាពជឿជាក់ខ្លាំងរវាងយុវជនយុវនារី គ្រួសារ និងបុគ្គលិក
- តំបន់គោលដៅនៃស្រុកទាំងពីរ (អង្គរជុំ និងអង្គរធំ) គឺជាតំបន់គោលដៅរបស់គម្រោងគាំទ្រ និងការពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់គ្រួសារស្រាប់ ជាហេតុនាំឱ្យភាពជឿជាក់របស់ប្រជាពលរដ្ឋមានកម្រិតខ្ពស់។
- កិច្ចសហការល្អជាមួយអជ្ញាធរមូលដ្ឋានគឺជាកត្តាជោគជ័យក្នុងការអនុវត្តន៍គម្រោង និងបង្កើននូវសាមគ្គីភាព។

## មេរៀនបទពិសោធន៍

- យុវជនយុវនារីមានការងារសមរម្យ ឬបានបង្កើតអាជីវកម្មដោយខ្លួនឯងដោយមានការគាំទ្រពីគម្រោងពិតជាបានឆ្លុះបញ្ចាំងពីភាពជោគជ័យរបស់យុវជនយុវនារី និងជាគម្រូដ៏ល្អដល់យុវជនយុវនារីផ្សេងទៀត និងអាចទាក់ទាញយុវជនយុវនារីនៅក្នុងសហគមន៍ ឱ្យផ្លាស់ប្តូរឥរិយាបទរបស់ពួកគេពីការធ្វើចំណាកស្រុកដោយគ្មានជំនាញ។
